


# ឌីញូស៍៖ វេទិការក្សាការចងចាំអំពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*ដោយ៖ នេន ស្រីមុំ, ភា រស្មី, សុភ័ក្ត្រ ភាណា, ស្រ៊ាង លីហ្ស៊ួរ និងអេង សុខម៉េង*

ឆ្នាំ២០២៥ គឺជាឆ្នាំគួរជាទីកត់សម្គាល់ ពីព្រោះឆ្នាំ២០២៥ គឺជាខួបលើកទី៥០នៃការឡើងកាន់អំណាចរបស់ខ្មែរក្រហម ដែលមានឈ្មោះជាផ្លូវការថា «កម្ពុជាប្រជាធិបតេយ្យ» នៅក្នុងប្រទេសកម្ពុជា និងជាខួបទី៣០របស់មជ្ឈមណ្ឌលឯកសារកម្ពុជា[1] ដែលជាស្ថាប័នឈានមុខក្នុងការចងក្រងឯកសារ និងរក្សាការចងចាំអំពីរបបខ្មែរក្រហម។ នៅក្នុងរយៈពេលប្រមាណជិតបួនឆ្នាំប៉ុណ្ណោះនៃការកាន់អំណាចរបស់ខ្លួន របបកម្ពុជាប្រជាធិបតេយ្យ បានផ្តាច់ជីវិតប្រជាជនកម្ពុជាអស់ចន្លោះពី១.៤ ទៅ២.២លាននាក់ តាមរយៈការសម្លាប់, ការបង្អត់អាហារ និងការងារដោយបង្ខំ។[2] ថ្វីត្បិតតែ របបនេះ បានបញ្ចប់អស់រយៈពេលជាង៤៥ឆ្នាំទៅហើយក្តី ការចងចាំពីបទពិសោធន៍ឈឺចាប់ អមជាមួយនឹងជំងឺផ្លូវកាយ និងផ្លូវចិត្តជាច្រើន នៅតែបន្តលងបន្លាចអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

យោងតាមរបាយការណ៍ សំយោគចេញពីការស្រង់មតិក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ៣២០០០នាក់ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តែងពើបប្រទះជាមួយជំងឺមិនឆ្លងចំនួន ១០មុខសំខាន់ៗ ដូចជា ជំងឺលើសឈាម, ជំងឺក្រពះពោះវៀន, ជំងឺគ្រុនចាញ់, ជំងឺផ្លូវចិត្ត, ជំងឺបេះដូង, ជំងឺរលាកសន្លាក់, ជំងឺហឺតរ៉ាំរ៉ៃ, ជំងឺទឹកនោមផ្អែម, ជំងឺរបេង និងជំងឺឆ្កួតជ្រូក។[3] ខណៈដែលជំងឺទាំងអស់នេះ ក្លាយជាផ្នែកមួយនៃវិបត្តិប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អ្នកទាំងនេះ ក៏កំពុងជួបប្រទះជាមួយនឹងការចម្រើនវ័យទៅមុខ។ អ្នករស់រានមានជីវិតដែលធ្លាប់បានផ្តល់បទសម្ភាសដល់មជ្ឈមណ្ឌលឯកសារកម្ពុជា មួយចំនួន បានបាត់បង់ជីវិតទៅហើយ។ ហេតុនេះ ការងារចងក្រងឯកសារ ជាពិសេសការប្រមែប្រមូលរឿងរ៉ាវជីវិតផ្ទាល់ខ្លួនរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម កាន់តែគួរផ្តោតការយកចិត្តទុកដាក់ជាងមុខឱ្យកាន់តែខ្លាំងឡើង ពីព្រោះថា យើងកំពុងប្រណាំងប្រជែងជាមួយពេលវេលា។ ដូច្នេះ ការប្រមែប្រមូលចងក្រងរឿងរ៉ាវជីវិត ឬប្រវត្តិសាស្ត្រផ្ទាល់របស់អ្នករស់រានមានជីវិតស្តីពីរបបខ្មែរក្រហម កាន់តែមានសារសំខាន់ឡើង។

យោងតាមវចនានុក្រម អកហ្វឺដ ប្រវត្តិសាស្ត្រផ្ទាល់មាត់ (Oral History) គឺជាការប្រមែប្រមូល និងសិក្សាអំពីព័ត៌មានប្រវត្តិសាស្ត្រ តាមរយៈការប្រើប្រាស់ការថតសំឡេងនូវបទសម្ភាសជាមួយនឹងមនុស្សទាំងពួងដែលបានចងចាំអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ។[4] ប្រវត្តិសាស្ត្រផ្ទាល់មាត់ មានសារប្រយោជន៍លើស

---

[1] www.dccam.org

[2] «អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក» ឆ្នាំ២០២០ ដោយ គ្រីស្តូហ្វ័រ ឌៀរីង និងអ្នកនិពន្ធដទៃទៀត, គ្រង់ជំពូកស្តីអំពីកម្ពុជា, ទំពរទី២៩, បោះពុម្ពផ្សាយដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា។

[3] «ព័ត៌មានអំពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពផ្សាយឆ្នាំ២០២៣។

[4] https://www.oxfordlearnersdictionaries.com/definition/english/oral-history#:~:text=%2F%CB%8C%C9%94%CB%90r%C9%99l%20%CB%88h%C9%AAstri%2F-,%2F%CB%8C

ពីនេះ ដោយប្រវត្តិសាស្ត្រផ្ទាល់មាត់ បានក្លាយជាមូលដ្ឋានដ៏សំខាន់ក្នុងការរៀបរាប់សាច់រឿងទៅកាន់មនុស្សជំនាន់ក្រោយអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ជាពិសេសប្រវត្តិសាស្ត្រដ៏ជូរចត់ ដែលពិបាកនឹងនឹកស្មានដល់។ ប្រវត្តិសាស្ត្រផ្ទាល់មាត់ ឬបទពិសោធន៍ឆ្លងកាត់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក៏បានដើរតួនាទីយ៉ាងសំខាន់ជាសក្ខីកម្មនៅក្នុងដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថែមទៀតផង។ ជាអកុសល មិនមែនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ សុទ្ធតែអាចផ្តល់សក្ខីកម្មនៅខាងមុខសវនាការទាំងអស់ឡើយ។

នៅក្នុងឆ្នាំ២០២០ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតជាគម្រោង «**ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម**» [5] ដែលធ្វើការសិក្សាស្រាវជ្រាវផ្ទាល់អំពីស្ថានភាពសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបន្ទាប់មក ធ្វើការប្រែក្លាយលទ្ធផលរកឃើញឱ្យទៅជាយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខភាព សុខុមាលភាព និងភាពសុខស្រួល របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេស។ គម្រោងនេះ ថែមទាំងរក្សាការចងចាំអំពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឱ្យបានទូលំទូលាយ តាមរយៈការបណ្តុះបណ្តាលយុវជន-យុវនារីជំនាន់ថ្មីក្នុងការប្រមែប្រមូលចងក្រងប្រវត្តិសាស្ត្រផ្ទាល់មាត់នៃបទពិសោធន៍នៅក្នុងរបបខ្មែរក្រហម ក្នុងគោលបំណងអប់រំមនុស្សជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៃរបបខ្មែរក្រហម ឈានទៅទប់ស្កាត់របបនេះពីការវិលត្រលប់សាជាថ្មី និងផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងគោលដៅលើកកម្ពស់ការយល់ដឹងជាទូទៅអំពីផលវិបាកនៃរបបខ្មែរក្រហមដែលបានបន្សល់ទុកនៅក្នុងប្រទេសកម្ពុជា។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា មានប្រសាសន៍ថា៖ «សោកនាដកម្ម និងភាពអយុត្តិធម៌ ដែលប្រជាជនកម្ពុជាទទួលរងនៅក្នុងរបបខ្មែរក្រហម មានទំហំមហាសាលដែលគ្មានអ្វីអាចជំនួសឬប៉ះប៉ូវជូនអ្នកទាំងអស់បានទេ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងមួយនេះ គឺជាជំហានឆ្ពោះទៅសម្រេចបានការថែទាំ និងគាំពារដល់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដោយគម្រោងនេះ រួមបញ្ចូលនូវអ្នកស្ម័គ្រចិត្តប្រកបដោយភាពមោះមុត ដែលបំពេញការងារនៅទូទាំងប្រទេស ក្នុងការជួយនាំអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិឋានរបស់ខ្លួនទៅមន្ទីរសុខភាពក្នុងសហគមន៍។ តាមរយៈការងារស្ម័គ្រចិត្តនេះ យុវជន-យុវនារី ទទួលបានឱកាសបង្ហាញចេញនូវភាពជាអ្នកដឹកនាំ រួមជាមួយនឹងការបំពេញការងារដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីគាំពារដល់អ្នករស់

%C9%94%CB%90r%C9%99l%20%CB%88h%C9%AAstri%2F,are%20not%20recorded%20in%20documents.

[5] សេចក្តីប្រកាសព័ត៌មានអំពីគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។

រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាចំពោះប្រជាជាតិកម្ពុជា។ ទន្ទឹមនឹងនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានឱកាសចែករំលែករឿងរ៉ាវឆ្លងកាត់ផ្ទាល់ខ្លួន នៅក្នុងអំឡុងរបបខ្មែរក្រហម ទៅកាន់ក្មេងជំនាន់ក្រោយ ដើម្បីជានាថាយើងនៅតែចងចាំពេលវេលាដ៏លំបាកយ៉ាងខ្លាំងមួយនោះ។ ជារួមគម្រោងនេះនឹងរំលេចនូវចរិកមនុស្សធម៌របស់យើង និងពង្រឹងបន្ថែមនូវស្មារតីមិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជ»។[6]

គម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» បានជ្រើសរើសយុវជន-យុវនារីកម្ពុជា ចំនួន **៣ ៤៦៤ រូប** និងបានជួបសម្ភាសអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទូទាំងប្រទេសចំនួន **៦១ ៦២៥រូប** ក្នុងចិរវេលា ៤ឆ្នាំកន្លងមក។[7] យុវជន-យុវនារី ដែលត្រូវបានជ្រើសរើសជាអ្នកស្ម័គ្រចិត្តកម្ពុជា គឺជាប្រជាជនកម្ពុជាដែលមានអាយុចន្លោះពី ១៨ ដល់ ២៥ឆ្នាំ មានការចង់ចេះចង់ដឹងអំពីប្រវត្តិសាស្ត្រ និងទទួលបានការបណ្តុះបណ្តាលអំពីវិធីសាស្ត្រក្នុងការធ្វើសម្ភាសប្រកបដោយវិជ្ជាជីវៈជាមួយនឹងបុគ្គលិកជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅមុនពេលចាប់ផ្តើមបំពេញការងារ។ ខុសប្លែកពីការសិក្សារៀនសូត្រនៅក្នុងថ្នាក់រៀនអំពីមេរៀនប្រវត្តិសាស្ត្រ អ្នកស្ម័គ្រចិត្តកម្ពុជា ទទួលបានចំណេះដឹងប្រវត្តិសាស្ត្រស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ តាមវិធីសាស្ត្រទំនើបដោយផ្តល់នូវការយល់ដឹង និងការត្រិះរិះពិចារណា។ អ្នកស្ម័គ្រចិត្តកម្ពុជា មានជំនាញ និងកម្រិតសិក្សាចម្រុះ ដែលរួមបញ្ចូលសិស្សកម្រិតវិទ្យាល័យ និងនិស្សិតសាកលវិទ្យាល័យ ក៏ដូចជាទាំងមុខវិជ្ជាសង្គម និងវិទ្យាសាស្ត្រ គឺចាប់ពីជំនាញអក្សរសាស្ត្រខ្មែរ រហូតដល់ជំនាញវេជ្ជសាស្ត្រ។

ដោយសារតែមានប្រវត្តិនៃការសិក្សា និងប្រវត្តិសាវតារខុសៗពីគ្នា អ្នកស្ម័គ្រចិត្តកម្ពុជា ទទួលបានកម្រិតនៃការយល់ដឹងពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យខុសៗពីគ្នា ក៏ប៉ុន្តែទោះបីជាយ៉ាងណាក្តី អ្នកស្ម័គ្រចិត្តទាំងនេះសុទ្ធសឹងតែអាចទទួលបានព័ត៌មានបឋមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្ទាល់, ទទួលបានចំណេះដឹងអំពីការធ្វើបទសម្ភាសន៍ ក៏ដូចជាការបំពាក់បំប៉នភាពជាអ្នកដឹកនាំតាមរយៈសកម្មភាពអប់រំផ្សេងៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោយពីបញ្ចប់ការងារជាអ្នកស្ម័គ្រចិត្តកម្ពុជា។ ក្រៅពីការចុះសម្ភាស និងសង្ខេបសាច់រឿង អ្នកស្ម័គ្រចិត្តកម្ពុជា ក៏ទទួលបានឱកាសចូលរួមនៅក្នុងការប

---

[6] ដូចខាងលើ

[7] ទិន្នន័យសំយោគចេញពីផែនទីបង្ហាញអំពីតួលេខនៃគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សូមមើល៖ https://www.dccam.org/wp-content/uploads/00_Homepage/Advancing-the-Rights-and-Improving-the-Conditions-of-the-Health-of-Khmer-Rouge-Survivors-maps.pdf

ណ្តុះបណ្តាលអំពីចំណេះដឹងផ្នែកវេជ្ជសាស្ត្រ[8], សិក្ខាសាលាស្តីពី «វប្បធម៌ការទូត»[9], ដំណើរទស្សនកិច្ចតាមរថភ្លើង[10] និងសន្និសីទលើកទី១ «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»[11] ដែលស្ថិតក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីពង្រីកវិសាលភាពនៃសមិទ្ធផលគម្រោង វេទិកាផ្សព្វផ្សាយមួយដែលមានឈ្មោះថា «ឌឺញូស៍» (https://thekrsurvivors.news/) បានចាប់បដិសន្ធិឡើងនៅក្នុងឆ្នាំ២០២៣។ សារព័ត៌មាន «ឌឺញូស៍៖ រឿងរ៉ាវនៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» បានបម្រើមុខងារជាវេទិកាមួយដ៏មានសារសំខាន់ក្នុងការអប់រំតាមរយៈការបង្ហាញទិដ្ឋភាពនៃការរស់នៅពីអតីតកាលឱ្យកាន់តែច្រើន និងកាន់តែច្បាស់លាស់ ព្រមទាំងចងក្រង និងចុះផ្សាយរឿងរ៉ាវជីវិតអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីទូទាំងប្រទេសកម្ពុជានៅលើគេហទំព័ររបស់ខ្លួនជារៀងរាល់សប្តាហ៍។ ដោយប្រើប្រាស់កម្រងសំណួរ និងសាច់រឿងដែលប្រមូលដោយអ្នកស្ម័គ្រចិត្តកម្ពុជា (CamboCorps)[12] របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមូលដ្ឋាននៃការសរសេររឿងរ៉ាវនៃប្រវត្តិសាស្ត្រផ្ទាល់មាត់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គេហទំព័រឌឺញូស៍ រួមបញ្ចូលនូវខ្លឹមសារពហុទម្រង់ជាភាសាខ្មែរ ដែលរួមមាន អត្ថបទខ្លី, អត្ថបទវែង, អត្ថបទស្រាវជ្រាវ និងវីដេអូខ្លីៗ ដោយផ្តោតទៅលើបទពិសោធន៍ជីវិតនៅក្នុងរបបខ្មែរក្រហម របស់អ្នករស់រានមានជីវិតពីរបបនេះ។

ប្រវត្តិសាស្ត្រផ្ទាល់មាត់ ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងការចូលរួមដោយយុវជន-យុវនារី ដែលជាអ្នកស្ម័គ្រចិត្តកម្ពុជា បានផ្តល់ឱកាសក្នុងការស្វែងយល់ពីស្ថានភាពរស់នៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ពីអតីតកាល និងបច្ចុប្បន្នកាលបន្ថែមទៀត ដោយផ្អែកទៅលើទិន្នន័យដែលប្រមូលបានមកពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេស។ នៅពេលដែលអ្នកស្ម័គ្រចិត្តកម្ពុជា សួរអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថា «តើអ្នកចងចាំអ្វីជាងគេនៅពេលនោះ?» ជាធម្មតា គឺ

---

[8] A Note of Cultural Diplomacy Forum November 16th-17th, 2023, please see: https://www.dccam.org/rights-and-welfare-of-khmer-rouge-survivor/

[9] CamboCorps Forum Report September 15th - 19th, 2023, please see: https://www.dccam.org/rights-and-welfare-of-khmer-rouge-survivor/

[10] របាយការណ៍សរុបស្តីពីទស្សកិច្ចសិក្សាតាមរថភ្លើងរបស់អ្នកស្ម័គ្រចិត្តកម្ពុជា៖ https://www.dccam.org/wp-content/uploads/03_Healing/Rights_and_Welfare_of_Khmer_Rouge_Survivor/PDF/Forced-Transfer-28-March-2024_8-Apr-2024.pdf

[11] www.dccamconference.org

[12] ងារ នៃអ្នកស្ម័គ្រចិត្តបំពេញការងារនៅក្នុងគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

តែងទទួលបានចម្លើយទាក់ទងទៅនឹងអំពើដ៏ឃោរឃៅដែលកើតមានឡើងក្នុងជីវិតប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតនៅក្រោមរបបនោះ។

ស្ថានភាពរស់នៅ ស្ថិតក្នុងចំណោមអ្វីដែលអ្នករស់រានមានជីវិតចងចាំបំផុតក្នុងជីវិតរបស់គាត់។ ការសង្កត់ធ្ងន់លើតម្លៃនៃរឿងផ្ទាល់ខ្លួននៃអ្នករស់រានមានជីវិត ដើម្បីយល់ដឹងអំពីអំពើប្រល័យពូជសាសន៍ គឺជារឿងសំខាន់។ឆ្លងកាត់រយៈកាលជាងមួយឆ្នាំកន្លងមក ក្រុមការងារ ឌីញូស៍ បានអាន និងផលិតមាតិកាចេញពីសាច់រឿងជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបានបំពេញការងាររួមគ្នាជាមួយនឹងមនុស្សជំនាន់ក្រោយនៃក្រុមនេះ ដែលជាអ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅក្នុងកម្រងឯកសារនេះ ក្រុមការងារ ឌីញូស៍ ចង់រំលេចនូវសាច់រឿងរបស់អ្នករស់រានមានជីវិតមួយចំនួន ដែលគួរជាទីចាប់អារម្មណ៍ និងប្រមែប្រមូលមកពីទីតាំងនានានៅទូទាំងប្រទេសកម្ពុជា ក៏ដូចជាព័ត៌មានស្តីពីការអនុវត្តទៅនៅក្នុងតំបន់គ្រប់គ្រងនីមួយៗរបស់ខ្មែរក្រហម។

### *ការធ្វើការងាររបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម*

នៅអំឡុងពេលវឹកវរក្នុងប្រវត្តិសាស្ត្រកម្ពុជា ចន្លោះពីឆ្នាំ១៩៧០-១៩៧៥ ប្រជាជនភាគច្រើនដែលរស់នៅតាមតំបន់រំដោះរបស់ខ្មែរក្រហមត្រូវបានរៀបចំឱ្យទៅជា «ក្រុមប្រវាស់ដៃ» ដែលមានសមាជិកពី ១០ ទៅ៣០គ្រួសារក្នុងមួយក្រុម។ ទោះជាយ៉ាងនេះក៏ដោយ ចាប់ពីឆ្នាំ១៩៧៣ និងជាពិសេសបន្ទាប់ពីជ័យជម្នះឆ្នាំ១៩៧៥ ក្រុមប្រវាស់ដៃត្រូវបានរៀបចំឱ្យទៅជា «សហករណ៍កម្រិតទាប» ដែលមានសមាជិកពី ៣០០ ទៅ៤០០នាក់ ឬក៏ភូមិមួយទាំងមូល។ រហូតដល់ឆ្នាំ១៩៧៧ សហករណ៍កម្រិតទាប ត្រូវបានរៀបចំឡើងវិញឱ្យក្លាយជា «សហករណ៍កម្រិតខ្ពស់» ដែលរួមមាន ១ពាន់គ្រួសារក្នុងសហករណ៍នីមួយៗ ឬក៏ឃុំមួយទាំងមូល។ សហករណ៍ត្រូវបានរៀបចំឡើងដើម្បីឱ្យមនុស្សចេះជួយខ្លួនឯងដោយមិនពឹងផ្អែកអ្នកដទៃ។ មេដឹកនាំខ្មែរក្រហម បានពិពណ៌នាសហករណ៍ថា «កម្លាំងដ៏អស្ចារ្យ» ក្នុងការកសាងប្រទេស និងជា «កំផែងដែកថែបយ៉ាងរឹងមាំបំផុត» សម្រាប់ការពារកម្ពុជាប្រជាធិបតេយ្យទប់ទល់នឹងសត្រូវ។[13]

ម្យ៉ាងវិញទៀត នៅអំឡុងពេលកាន់កាប់របស់ខ្មែរក្រហម ក្រៅពីការបែងចែកឱ្យមានសហករណ៍ប្រវាស់ដៃ ក៏មានការប្រមូលយកទ្រព្យសម្បត្តិរបស់ប្រជាជនកម្ពុជាទាំងអស់ដាក់ជាសមូហភាព។ ប្រជាជនទាំងអស់ត្រូវប្រមូលយករបស់របរដែលខ្លួនមានទាំងអស់ដាក់ជារបស់រួម ហើយគ្មានប្រជាជនណាម្នាក់អាចរក្សាទុកទ្រព្យសម្បត្តិឯកជនឡើយ។ ក្នុងករណីដែលអង្គការបានដឹងថា គ្រួសារណាមួយលួចរក្សាទុកទ្រព្យផ្ទាល់ខ្លួន អង្គការនឹងបញ្ជូនកងឈ្លបទៅប្រមូលយក ឬអាចចាប់យកគ្រួសារមួយនោះទៅកសាង។ ជាមួយគ្នានេះដែរ សមាជិកគ្រួសារទាំងអស់ត្រូវបានអង្គការបំបែកឱ្យរស់នៅ និងធ្វើការផ្សេងពីគ្នា ហើយមិនងាយ

---

[13] ផេង ពង្សរ៉ាស៊ី et al. (២០២០) , *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)* , បោះពុម្ពលើកទី២, ភ្នំពេញ, មជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រទី៣៩-៤០។

បានជួបសួរសុខទុក្ខគ្នាឡើយ។ គ្រួសារដែលធ្លាប់តែរស់នៅជួបជុំគ្នា ត្រូវបង្ខំឱ្យរស់នៅបែកខ្ញែកពីគ្នា។ អង្គការ បានប្រកាសជាសាធារណៈទៅកាន់ប្រជាជនដែលបានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ឱ្យខិតខំធ្វើការងារដោយមិនត្រូវគិតអំពីប្រាក់ខែនោះទេ។ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៨ វិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យបានប្រកាសថា៖ «ប្រជាកសិកររបស់យើងដែលអនុវត្តតាមរបបសមូហភាពនិយម ប្រជាកសិករ និងយុទ្ធជនរបស់យើងបានវាយប្រយុទ្ធដើម្បីបម្រើប្រជាជន និងប្រជាជាតិ សមស្របទៅតាមបេសកកម្មផ្ទាល់ខ្លួនម្នាក់ៗ ដោយគ្មានបានទទួលផលប្រយោជន៍ផ្ទាល់ខ្លួនក្រោមទម្រង់ជាប្រាក់ខែ ឋានៈ តួនាទី កិត្តិនាម ឬឋានន្តរស័ក្តិបន្តិចណាឡើយ។ អ្នកទាំងនេះតែងតែយកចិត្តទុកដាក់ចំពោះសេរីភាព ឯកភាព សហករណ៍របស់ខ្លួន និងប្រជាជាតិទាំងមូលតែម្យ៉ាងគត់ ដោយញែកប្រការទាំងនេះដាច់ស្រឡះពីកម្មសិទ្ធិឯកជន»។ បទវិចារណកថារបស់វិទ្យុពុំមាននិយាយពាក្យបញ្ចិតបញ្ចៀងណាមួយចំពោះលក្ខខណ្ឌជីវភាពខាងសម្ភារជាឯកជន ឬជាសមូហភាព ដែលប្រមូលផ្ដុំក្រោមផ្លាក «កម្មសិទ្ធិឯកជន» ឡើយ ដែលចាប់ពីពេលនេះទៅគឺជារបស់ដែលគេលែងត្រូវការ[14] ។

របបខ្មែរក្រហម គឺជារបបមួយដែលបានរុញច្រានប្រជាជនកម្ពុជាគ្រប់ស្រទាប់អាយុ មិនថាចាស់ ឬក្មេង ទៅក្នុងការដ្ឋានពលកម្មដោយបង្ខំ។ ការបង្ខិតបង្ខំឱ្យប្រជាជនធ្វើការលើសពីសមត្ថភាព គឺជាការប្រឈមមួយយ៉ាងធំដែលអាចបណ្ដាលឱ្យប្រជាជនងាយនឹងមានជំងឺ និងស្លាប់បាត់បង់ជីវិត។ ប្រជាជនគ្រប់រូបក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាត់តាំងឱ្យធ្វើការទាំងអស់។ កុមារត្រូវធ្វើការងារស្រាលៗ។ ចំណែកមនុស្សចាស់ត្រូវទទួលតួនាទីមើលថែទាំងកុមារតូចៗ និងសត្វពាហនៈ ព្រមទាំងត្បាញកញ្ច្រែងល្អី។ មនុស្សដែលពេញកម្លាំង ត្រូវបានអង្គការចាត់តាំងឱ្យធ្វើការងារធ្ងន់ៗ និងលំបាក ដូចជា៖ ជីកប្រឡាយ ឬអាងស្តុកទឹក, លើកទំនប់, កាប់ឈើធ្វើផ្ទះ, រានដីដើម្បីធ្វើស្រែចម្ការ ក៏ដូចជាដាំ និងច្រូតកាត់ស្រូវ។ បុរស ស្ត្រី ដែលបក្សទុកចិត្ត ត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅរោងចក្រងទីក្រុងភ្នំពេញ។ ប្រជាជនស្ទើរគ្រប់រូបធ្វើការច្រើនជាង ១២ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្ដាហ៍ ដោយគ្មានពេលសម្រាក និងពុំបានទទួលទានអាហារបានគ្រប់គ្រាន់ឡើយ។ ប្រជាជន ជួនកាល ត្រូវធ្វើការតាំងពីព្រលឹមស្រាងៗរហូតដល់ពាក់កណ្ដាលយប់ទើបឈប់សម្រាក។ នៅក្នុងខែងងឹតដែលគ្មានពន្លឺខែ ប្រជាជនត្រូវអុជភ្លើងបំភ្លឺវាលស្រែដើម្បីធ្វើការងារកសិកម្ម[15] ។

ខ្មែរក្រហមមានបំណងអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យមានភាពរីកចម្រើនខាងវិស័យកសិកម្ម ដែលអាចរាប់បញ្ចូលថា សង្គមថ្មីដែលមានកម្រិតជីវភាពខ្ពស់ក្នុងរយៈពេល ៣ឆ្នាំ។ ការអភិវឌ្ឍប្រទេសនៅ

---

[14] ប៊ែន ឃៀនិន, (២០០៨) ,*របប ប៉ុល ពត*, ប្រែសម្រួលដោយ ឡាយ ពុទ្ធារ៉ា និង ទីយាយុ, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទំព័រទី៣៣៥។

[15] ផេង ពង្សរ៉ាស៊ី et al, (២០២០) ,*ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)* , បោះពុម្ពលើកទី២, ភ្នំពេញ, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទំព័រទី៤៧។

ជំហានដំបូងបំផុត ផ្ដើមចេញពីការធ្វើការដោយប្រើកម្លាំងមនុស្ស និងសត្វពាហនៈសុទ្ធសាធ គ្មានគ្រឿងយន្តជំនួយទេ។ ក្រៅពីនេះខ្មែរក្រហម បានកសាងកម្ពុជាមួយថ្មីដែលពឹងផ្អែកទៅលើការពង្រីកផលិតកម្មស្រូវនៅក្នុងប្រទេសកម្ពុជា។ នៅដើមឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានប្រញាប់ប្រញាល់រៀបរៀងផែនការបួនឆ្នាំលើកទី១(១៩៧៧-១៩៨០) ដែលតម្រូវឱ្យធ្វើការប្រមូលផ្ដុំទ្រព្យសម្បត្តិឯកជនទាំងអស់ និងដាក់ដាំដុះស្រូវជាអាទិភាពចម្បងរបស់ជាតិ។ បន្ទាប់ពីបញ្ហាសន្តិសុខជាតិ សមូហភាវូបនីយកម្ម គឺជាគោលនយោបាយដ៏សំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ[16] ។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បាននិយាយពីសាច់រឿងទុក្ខលំបាករបស់គាត់ផ្សេងៗពីគ្នា ដោយមានប្រជាជនខ្លះជាកសិករនៅក្នុងសហករណ៍, ខ្លះជាយោធា និងខ្លះទៀតកម្មករនៅក្នុងរោងចក្រផ្សេងៗ។



ជាក់ស្ដែង អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ឈ្មោះ **ទេស សារុន** ភេទស្រី អាយុ ៦០ឆ្នាំ បច្ចុប្បន្ន រស់នៅភូមិព្រៃលៀប ឃុំព្រៃអំពក ស្រុកគីរីវង់ ខេត្តតាកែវ បានលើកឡើងថា នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមឡើងកាន់អំណាច គ្រួសាររបស់ សារុន ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញទៅកាន់តំបន់១០៩ ខេត្តតាកែវ។ សារុន ត្រូវចេញទៅធ្វើការងារនៅក្នុងសហករណ៍។ នៅរដូវប្រាំង អង្គការបានចាត់ឱ្យ សារុន ដេញចាប និងដឹកប្រឡាយនៅជិតៗភូមិ។ នៅរដូវវស្សា សារុន ត្រូវជួយធ្វើការងារដកស្ទូង, ច្រូតកាត់តាមរដូវ និងលាយជីលាមកមនុស្ស និងសត្វ រួចទូលយកទៅដាក់ក្នុងស្រែ។ នៅឆ្នាំ១៩៧៧ សារុន បានចូលទៅធ្វើការនៅក្នុងកងជំនួយ និងត្រូវជម្លៀសម្ដងទៀតទៅកាន់តំបន់១០៥។ តំបន់១០៥ ដែល សារុន ជម្លៀសទៅ ស្ថិតនៅត្រង់ថ្នល់បែកគូស ស្រុកត្រាំកក់។ កងជំនួយ របស់ សារុន ត្រូវធ្វើការដូចជា លើកទំនប់,

[16] ដូចខាងលើ ទំព័រទី៣៥។

ដឹកប្រឡាយ និងដកស្ទូង ដូចក្រុមនារីពេញកម្លាំងដែរ។ ក្រៅពីការងារស្ទូងដក អង្គការបានចាត់ សារុន ឱ្យទៅរកឧសនៅក្នុងព្រៃយកមកដាក់ក្នុងរោងបាយ។[17]

រីឯ **ណារ៉ា ហ្កា** ជាស្ត្រីកសិករចាម ដែលរស់នៅភូមិមួយស្ថិតនៅភូមិភាគនិរតី[18] បានប្រាប់ឱ្យដឹងថា «ការធ្វើទុកបុកម្នេញបានចាប់ផ្តើម» នៅខេត្តតាកែវ ក្រោយខែមេសា ឆ្នាំ១៩៧៥។ ប្រជាជនចាម និងខ្មែរនៅក្រុងភ្នំពេញបានទៅរស់នៅក្នុងភូមិចាមមួយនៅតំបន់នោះ។ តាំងពីពេលនោះមក អង្គការបានបង្ខំឱ្យអ្នកភូមិធ្វើការទាំងយប់ ទាំងថ្ងៃទៅតាមគម្រោងការផ្សេងៗ ដើម្បីបញ្ចូលទឹកក្នុងស្រែ។ នៅឆ្នាំ១៩៧៦ អង្គការបានបង្កើតការហូបបាយរួមនៅក្នុងភូមិចាមទាំងអស់ ហើយការដាំបន្លែជាបុគ្គល និងការដើររកម្ហូបអាហារបន្ថែម ត្រូវបានហាមឃាត់។ ម្ហូបអាហារខ្លះមានដាក់សាច់ជ្រូក ប៉ុន្តែជនជាតិចាមចាស់ៗមិនអាចបរិភោគបាននោះទេ។ ប្រធានភូមិចាមម្នាក់ឈ្មោះ ស៊ីម បានអនុញ្ញាតមិនឱ្យប្រជាជនចាមបរិភោគសាច់ជ្រូកទេ ប៉ុន្តែមិនបានយូរប៉ុន្មាន ស៊ីម ត្រូវបានអង្គការដកចេញពីតំណែង ដោយសារតែការសន្តោសប្រណីរបស់គាត់។[19]



---

[17] សម្ភាសន៍ជាមួយ ទេស សារុន ដោយ ថន ធារ៉ា, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១,មជ្ឈមណ្ឌលឯកសារកម្ពុជា។

[18] ផេង ពង្សរ៉ាស៊ី et al. (២០២០) , *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)* , បោះពុម្ពលើកទី២,ភ្នំពេញ។ មជ្ឈមណ្ឌលឯកសារកម្ពុជា, ទំព័រទី៣៤ *«ភូមិភាគនិរតី (ភូមិភាគ៤០៥) ដឹកនាំដោយ ឈិត ជឿន ហៅ តាម៉ុក។ ភូមិភាគនេះរួមមានខេត្តកំពត និងខេត្តតាកែវទាំងមូល ស្រុក ២ក្នុងខេត្តកំពង់ស្ពឺ គឺស្រុកសំរោងទង និងស្រុកគងពិសី និងស្រុក៥ក្នុងខេត្តកណ្តាល គឺស្រុកកណ្តាលស្ទឹង ស្រុកស្អាង ស្រុកកោះធំ ស្រុកកៀនស្វាយ និងស្រុកលើកដែក។ ភូមិភាគនេះ ចែកចេញជា៤ តំបន់គឺៈ តំបន់១៣ តំបន់៣៣ តំបន់៣៥ និងតំបន់២៥»។*

[19] ប៉ែន យៀនិន, (២០០៨). *របប ប៉ុល ពត*, ប្រែសម្រួលដោយ ឡាយ ពុទ្ធារ៉ា និង ទីឃាយុ, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទំព័រទី៤៤៥។

ចំណែកឯអ្នករស់រានមានជីវិតដែលបច្ចុប្បន្នរស់នៅភូមិឫស្សីចារ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ ឈ្មោះ **ឯក គីមសេន** បានលើកឡើងថា អង្គការបានចាត់ឱ្យគាត់ឱ្យរស់នៅផ្សេងពីសមាជិកគ្រួសារ។ អង្គការបានធ្វើការបែងចែកប្រជាជនឱ្យរស់នៅផ្សេងៗពីគ្នាតាមភេទ និងអាយុ។ គីមសេន បាននិយាយបន្ថែមថា នៅក្នុងរបបខ្មែរក្រហម កុមារៗគ្មានឱកាសទទួលបានការសិក្សាអប់រំទេ។ ផ្ទុយទៅវិញ កុមារត្រូវជួយធ្វើការងារផ្សេងៗ។ ចំណែកមនុស្សពេញវ័យគឺ ផ្ដោតលើការធ្វើការងារកសិកម្ម។ អំឡុងពេលនោះ គីមសេន ស្ថិតនៅក្នុងកងកុមារវ័យជំទង់ ហេតុនេះអង្គការបានចាត់ឱ្យគាត់ លើកភ្លឺស្រែ និងច្រូតស្រូវ ព្រមទាំងកាប់ទន្រ្ទានខេត្តសម្រាប់ធ្វើជី។ គាត់ត្រូវក្រោកទៅធ្វើការតាំងពីម៉ោង ៥ព្រឹក និងឈប់សម្រាកហូបអាហារថ្ងៃត្រង់នៅម៉ោង១២។ បន្ទាប់ពីហូបអាហារថ្ងៃត្រង់រួច នៅម៉ោងប្រហែល១រសៀល គឹមសេង ត្រូវទៅធ្វើការបន្ត រហូតដល់ម៉ោង៦ល្ងាចទើបបានឈប់សម្រាកហូបអាហារពេលល្ងាច និងពេលយប់ឡើងគាត់ត្រូវធ្វើការងារបន្ថែមទៀត គឺបោកស្រូវ និងបុកស្រូវរហូតដល់ម៉ោង៩យប់ទើបបានសម្រាកពីការងារ។[20]

## ជីលេខ១ (ជីលាមកមនុស្ស)

ជីលេខ១ ឬជីលាមកមនុស្ស គឺជាជីមួយប្រភេទដែលត្រូវបានចាត់ទុកថាជាប្រភេទជីល្អបំផុតនៅក្នុងរបបខ្មែរក្រហម។ ខ្មែរក្រហម បានប្រើឱ្យប្រជាជនជាច្រើនប្រមូលលាមកមនុស្សនៅតាមបង្គន់ ដើម្បីយកទៅហាលឱ្យស្ងួត ទុកលាយជាមួយនឹងជីដំបូក ឬដើមទន្រ្ទានខេត្ត និងកាកអំពៅ។ ជំហាននៃការលាយជី គឺដំបូងឡើយត្រូវយកលាមកដែលហាលស្ងួតនោះទៅបុកឱ្យល្អិត ហើយបន្ទាប់មកយកជីដំបូកដាក់ជាន់លាយឱ្យសព្វចូលគ្នា។ ផលលំបាករបស់ប្រជាជនដែលធ្វើការនៅក្នុងកងផលិតជីដែលបានជួបនៅអំឡុងពេលនោះ គឺភាគច្រើនទ្រាំមិនបានជាមួយនឹងក្លិនរបស់ជីនោះ ព្រោះវាមានក្លិនស្អុយខ្លាំងព្រមទាំងមានដង្កូវនៅក្នុងជីនោះដែរ។ ប្រជាជនមួយចំនួន ត្រូវខូចក្រចកជើងរបស់គាត់រហូតមកដល់សព្វថ្ងៃ ដោយសារគាត់ត្រូវប្រើជើងជាន់ ដើម្បីលាយជីឱ្យសព្វចូលគ្នាល្អ។ ការធ្វើការងារនៅក្នុងកងផលិតជី បានបណ្ដាលឱ្យប្រជាជនជាច្រើនមានជំងឺ ដោយសារតែគាត់ហូបអាហារមិនសូវបាន ព្រោះគាត់នៅតែមានអារម្មណ៍ថាក្លិនរបស់ជីនោះនៅតែជាមួយនឹងច្រមុះរបស់គាត់។ នៅក្នុងតំបន់មួយចំនួន អង្គការបានបញ្ជាឱ្យសមាជិកក្នុងកងធ្វើជីលេខមួយ ភ្លក់ជីមុនពេលដាក់ចូលស្រែថែមទៀតផង។[21] ខាងក្រោមនេះគឺជាការចែករំលែករបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ពាក់ព័ន្ធនឹងការផលិតជីលាមកមនុស្ស។

---

[20] សម្ភាសន៍ជាមួយ ឯក គីមសេន ដោយ យ៉ុង ផល្លីន,ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤, មជ្ឈមណ្ឌលឯកសារកម្ពុជា។

[21] សម្ភាសន៍ជាមួយ មាស លៀម ដោយ ឡាយ កូរ, ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤, មជ្ឈមណ្ឌលឯកសារកម្ពុជា។



**ដឹ អៀយ** សព្វថ្ងៃមានអាយុ ៥៥ឆ្នាំ រស់នៅភូមិឡាម៉ឺយ ឃុំកុកឡាក់ ស្រុកវើនសៃ ខេត្តរតនគិរី។ **អៀយ** គឺជាជនជាតិដើមភាគតិចការ៉ែត និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ទាក់ទងនឹងការធ្វើជី អៀយ បានលើកឡើងថា ដំបូងឡើយ ខ្មែរក្រហមបានឱ្យប្រជាជនជីកដីប្រវែង ៥ម៉ែត្រការ៉េ បន្ទាប់មកយកទន្រ្ទានខេត្តដែលកងកុមារចិញ្រ្ចាំរួចដាក់ចូលលាយជាមួយដីដំបូក និងចាក់លាមកសត្វ ឬលាមកមនុស្សពីលើ។ បន្ទាប់ពីផ្អាប់អស់រយៈពេលមួយសប្តាហ៍ទៅមួយខែក្រោយមក គេអាចយកជីទាំងនោះទៅប្រើប្រាស់សម្រាប់បាចដាក់តាមវាលស្រែ និងចម្ការ ដែលអាចជួយបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់។[22]

**សុខ សន** មានអាយុ៦៣ឆ្នាំ ជាកសិករ មានស្រុកកំណើត និងរស់នៅភូមិស្វាយតាភ្លួ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ក្នុងរបបខ្មែរក្រហម សន ត្រូវបានអង្គការបង្ខំឱ្យចេញពីលំនៅដ្ឋានដែលធ្លាប់រស់នៅជាមួយបង ដោយអង្គការតម្រូវឱ្យទៅរស់នៅរួមគ្នាក្នុងសហករណ៍។ គាត់ត្រូវធ្វើជីពីលាមកមនុស្ស។ នៅរៀងរាល់ព្រឹក គាត់ត្រូវដើរប្រមូលលាមកតាមបង្គន់យកមកហាល និងប្រមូលទុកនៅពេលល្ងាច។ គាត់ធ្វើការងារលាយជីលេខមួយបានមួយរយៈប៉ុណ្ណោះ ពីព្រោះ ជើងរបស់គាត់ឈឺមិនអាចធ្វើដំណើរបាន។ ក្រោយមក ខ្មែរក្រហម បានផ្លាស់គាត់ឱ្យនៅចាំសហករណ៍ ដើម្បីដាំបាយ, ដាំបបរ និងធ្វើម្ហូបសម្រាប់យុវជន-យុវនារីនៅក្នុងកងចល័តដែលធ្វើស្រែចម្ការវិញ។[23] សុខ សន ជាកូនពៅក្នុងគ្រួសារដែលមានបងប្អូនប្រាំមួយនាក់។ ឪពុក ម្តាយបានស្លាប់ចោលតាំងពីរបប លន់ នល់។ គាត់ត្រូវបានបងប្រុសចិញ្ចឹម ហើយបងប្រុសនោះត្រូវបានខ្មែរក្រហមសម្លាប់ចោលទាំងគ្រួសារក្នុងរបបខ្មែរក្រហម នៅឯខេត្តបាត់ដំបងដែលជាព្រឹត្តិការណ៍មួយគាត់ចងចាំមិនអាចបំភ្លេចបានរហូតដល់បច្ចុប្បន្ន។

ដោយឡែកប្រសិនជាយើងក្រឡេកទៅមើលប្រជាជនដែលជាអ្នកធ្វើការនៅក្នុងសហករណ៍ស្ទូងស្រូវវិញគាត់បានលើកឡើងថា អ្នកដែលមានតួនាទីជាអ្នកស្ទូងស្រូវនៅក្នុងរបបខ្មែរក្រហម គឺអង្គការតម្រូវ

---

[22] សម្ភាសន៍ជាមួយ ដឹ អៀយ ដោយ បេង ហង្ស, ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤, មជ្ឈមណ្ឌលឯកសារកម្ពុជា។

[23] សម្ភាសន៍ជាមួយ សុខ សន ដោយ សុខ ចន្ទ្រា, ថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១, មជ្ឈមណ្ឌលឯកសារកម្ពុជា។

ឱ្យយកសំណាបដែលត្រូវស្ទូង ទៅជ្រលក់ជីលេខ១ ឬជីលាមកមនុស្សសិនទើបឱ្យយកទៅស្ទូងនៅក្នុងស្រែ។ ប្រជាជនខ្លះដោយសារតែខ្ពើម និងចាញ់ក្លិនរបស់ជីលាមកនោះ ស្ទូងផង ក្អួតផង។ ថ្វីត្បិតតែគាត់ខ្ពើមយ៉ាងណាក្តី ក៏គាត់មិនហ៊ានបោះសំណាបនោះចោលឡើយ ព្រោះអង្គការតម្រូវឱ្យស្ទូងសំណាបនោះឱ្យអស់។ ដោយហេតុនេះហើយ សហករណ៍ស្ទូងស្រូវត្រូវអត់ធ្មត់ស្ទូងឱ្យអស់សំណាបនោះ។



**រ័ត្ន គីម** ភេទស្រី មានអាយុ ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ ខេត្តស្ទឹងត្រែង។ ការងារដែលគាត់ធ្វើជាប្រចាំថ្ងៃនោះគឺស្ទូងស្រូវ។ អង្គការបានប្រើឱ្យគាត់ យកសំណាបទៅជ្រលក់ជាមួយនឹងជីលាមកមនុស្ស។ គាត់បាននិយាយថា ជីនោះមានសុទ្ធតែដង្កូវ ហើយអង្គការមិនអនុញ្ញាតឱ្យអ្នកស្ទូងទាំងអស់យកសំណាបនោះដាក់ក្នុងទឹកទេ ព្រោះខ្លាចជីជ្រុះចេញពីសំណាប។ គាត់បានបន្ថែមថា នៅពេលដែលគាត់ចាប់សំណាបនោះយកទៅស្ទូង គាត់ខ្ពើមជីលាមកដែលជាប់នៅជាមួយនឹងសំណាបនោះណាស់ ប៉ុន្តែគាត់ត្រូវតែយកសំណាបនោះទៅស្ទូង ព្រោះខ្លាចអង្គការចាប់យកទៅសម្លាប់ចោល។[24] គីម បានរៀបរាប់អំពីហេតុការណ៍ដែលគាត់ធ្លាប់បានឆ្លងកាត់ផ្សេងៗទៀតក្នុងរបបខ្មែរក្រហមប្រាប់ទៅកាន់អ្នកស្ម័គ្រចិត្តកម្ពុជាថា គាត់ពិតជាវេទនាណាស់។ គាត់បាននិយាយថា របបមួយនោះ «គួរតែជីកកប់វាបំបាត់ចោលទៅ មិនគួររំឭកឡើងមកវិញនោះទេ» ព្រោះគាត់ឆ្អែតឆ្អន់ជាមួយនឹងរបបមួយនោះ។ របបនេះធ្វើឱ្យគាត់វេទនាខ្លោចផ្សា ព្រាត់ប្រាស់ឪពុកម្តាយ បងប្អូន។ របបនោះ គឺជារបបដ៏ឃោរឃៅ បានសម្លាប់វង្គាលជាតិសាសន៍ខ្លួនឯង។

**សោម សឿន** មានអាយុ ៧៣ឆ្នាំ មានមុខរបរជាកសិករ រស់នៅភូមិបាយ៉ាប ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ក្នុងរបបខ្មែរក្រហម សឿន មានអាយុប្រមាណជា ៣០ឆ្នាំ។ គាត់ និងប្តី ព្រមទាំងកូនរបស់គាត់ ត្រូវអង្គការឱ្យរស់នៅសហករណ៍ក្នុងភូមិ-ឃុំ ដែលគាត់រស់នៅសព្វថ្ងៃ។ សឿន ត្រូវធ្វើការដូចជាស្ទូង និងដកសំណាប។ ក្រៅពីការងារនេះ គាត់ត្រូវមើលការខុសត្រូវក្មេងៗក្នុងកងកុមារ ដែលមើលគោ ក្របី

---

[24] សម្ភាសន៍ជាមួយ រ័ត្ន គីម ដោយ ស្រេង លីដា, ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣, មជ្ឈមណ្ឌលឯកសារកម្ពុជា។

រើសអាចម៍គោ និងចិញ្ច្រាំរុក្ខជាតិផ្សេងៗយកទៅធ្វើជីសម្រាប់ដាក់ស្រែ។ ក្រោយមកអង្គការបានប្រើគាត់ឱ្យយកជីលេខមួយដែលផ្សំពីលាមកមនុស្សយកទៅបាចស្រូវមួយថ្ងៃឱ្យបានមួយហិចតា។[25]

## *ស្ថានភាពរស់នៅរបស់អ្នករស់រានមានជីវិត ក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម*

ខាងក្រោមនេះ គឺជាសាច់រឿងសង្ខេបពីជីវភាពរស់នៅរបស់អ្នករស់រានមានជីវិតតាមភូមិភាគ និងតំបន់ស្វយ័ត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ក្នុងនោះរួមមានភូមិភាគ និងតំបន់ស្វយ័តចំនួន ១១ ដូចជា ភូមិភាគបូព៌ា (ភូមិភាគ២០៣), ភូមិភាគនិរតី (ភូមិភាគ៤០៥), ភូមិភាគឧត្តរ (ភូមិភាគ៣០៣), ភូមិភាគពាយ័ព្យ (ភូមិភាគ៥៦០), ភូមិភាគបស្ចិម (ភូមិភាគ៤០១), ភូមិភាគឦសាន (ភូមិភាគ១០៨), តំបន់សៀមរាប-ឧត្តរមានជ័យ (តំបន់១០៦), តំបន់ព្រះវិហារ (តំបន់១០៣), ក្រុងកំពង់សោម, តំបន់ក្រចេះ (តំបន់៥០៥) និង តំបន់មណ្ឌលគិរី (តំបន់១០៥)។[26]



*បទពិសោធន៍របស់អ្នករស់រានមានជីវិតពីភូមិភាគបូព៌ា (ភូមិភាគ២០៣)*

**ប្រាជ្ញ ធឿន** មានអាយុ ៧៤ឆ្នាំ រស់នៅភូមិក្បាលក្រពើ ឃុំអង្គប្រស្រែ ស្រុករមាសហែក ខេត្តស្វាយរៀង។ នៅឆ្នាំ១៩៧៥ ធឿន មានអាយុ ៣០ឆ្នាំ។ នៅពេលនោះ យោធាខ្មែរក្រហម បានបង្ខំឱ្យគាត់ និងប្រជាជនចាកចេញពីផ្ទះសំបែងទៅរស់នៅតាមសហករណ៍។ ប្រជាជនត្រូវធ្វើស្រែ ជីកទំនប់ លើកប្រឡាយ និងលើកភ្លឺស្រែ។ ធឿន ត្រូវបានចាត់តាំងជាកងកម្លាំងស្នូល ឬកងកម្លាំងស្រួច ដែលត្រូវធ្វើពលកម្មនៅតាមសហករណ៍ផ្សេងទៀត។ ធឿន ទទួលបានត្រឹមតែបាយមួយវែកក្នុងមួយពេល និងពីរពេលក្នុងមួយថ្ងៃ។

[25] សម្ភាសន៍ជាមួយ សោម សឿន ដោយ ពេជ សាន. ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១, មជ្ឈមណ្ឌលឯកសារកម្ពុជា។

[26] ផេង ពង្សរ៉ាស៊ី, et al, (២០២០), ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), បោះពុម្ពលើកទី២, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទំព័រទី៣៣-៣៥។

អ្នកដែលលួចបេះផ្លែឈើហូប នឹងត្រូវចោទថាជាខ្មាំងក្បត់អង្គការ។ ធឿន បានលើកឡើងបន្ថែមទៀតថា « បើមិនស្លាប់ដោយសារគេយកទៅសម្លាប់ក៏ត្រូវស្លាប់ដោយសារការអត់ឃ្លាន និងធ្វើការហួសកម្លាំងដែរ» ។[27]

## *បទពិសោធន៍របស់អ្នករស់រានមានជីវិតពីភូមិភាគនិរតី (ភូមិភាគ៤០៥)*

**ជ័យ យ៉ា** មានអាយុ ៧៤ឆ្នាំ រស់នៅភូមិសម៉ខ្មែរ ឃុំពាធីរចោក ស្រុកព្រៃកប្បាស ខេត្តតាកែវ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់យ៉ាត្រូវបានយោធាខ្មែរក្រហមជម្លៀសចេញពីគេហដ្ឋានឱ្យទៅរស់នៅក្នុងវត្តមួយកន្លែង។ យ៉ា រំឭកថា នៅវត្តនោះ ព្រះសង្ឃត្រូវចាប់ផ្សឹក និងបង្ខំឱ្យធ្វើការដោយគ្មានពេលឈប់សម្រាកដូចប្រជាជនទូទៅដែរ។ យ៉ា ត្រូវធ្វើការហួសកម្លាំងទាំងមានផ្ទៃពោះ ហើយទទួលបានតែបបរ ឬបបរលាយជាមួយផ្លែខ្វិតជាអាហារ និងទទួលបានត្រឹមអាហារពីរពេលតែប៉ុណ្ណោះក្នុងមួយថ្ងៃ។ អ្នកដែលខ្មែរក្រហមចោទថាខ្ជិល ត្រូវរងទារុណកម្ម។ ឯអ្នកដែលមានជំងឺ គ្មានថ្នាំព្យាបាលត្រឹមត្រូវទេ ពោលគឺមានតែថ្នាំដែលមានរូបរាងដូចអាចម៍ទន្សាយ។ ដើម្បីរស់ យ៉ា បានលួចបេះបន្លែបង្ការហូប។ យ៉ា ត្រូវរស់នៅដោយហូបចុកមិនគ្រប់គ្រាន់ និងធ្វើការហួសកម្លាំងដូចប្រជាជនឯទៀតដែរ។[28]

## *បទពិសោធន៍របស់អ្នករស់រានមានជីវិតពីភូមិភាគឧត្តរ (ភូមិភាគ៣០៣)*



[27] អេង សុខម៉េង, (២០២៤) ,ជីវិតថ្លៃ, សម្ភាសជាមួយ ប្រាជ្ញ ធឿន ដោយ ព្រាប ច័ន្ទពិសី នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/prach-thoeun/

[28] នេន ស្រីមុំ, (២០២៤) , បបរលាយផ្លែខ្វិត, សម្ភាសជាមួយ ជ័យ យ៉ា ដោយ ចឹក ចាន់ណា នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០២៣។ មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/chey-ya/

**ផើវ ឡាំ** មានអាយុ ៧៣ឆ្នាំ ជាជនជាតិដើមភាគតិចការ៉ែត រស់នៅភូមិឡាម៉ឺយ ឃុំកុកឡាក់ ស្រុកវើនសៃ ខេត្តរតនគិរី។ ឡាំ ត្រូវបានខ្មែរក្រហមជម្លៀសឱ្យទៅរស់នៅក្នុងសហករណ៍តូចមួយស្ថិតនៅក្នុងខេត្តកំពង់ធំ ភូមិភាគឧត្តរ។ ឡាំ ត្រូវរស់នៅរួម ហូបរួម និងធ្វើការរួម ដោយបែកពីសមាជិកគ្រួសារ ហើយត្រូវទៅធ្វើការជាមួយក្រុមត្បាញកន្ទេល។ ក្រៅពីការងារនេះ ពីព្រឹកព្រលឹមរហូតយប់អធ្រាត្រ ឡាំ ត្រូវទៅធ្វើស្រែ, កាប់ឆ្ការព្រៃ, ធ្វើជីលាមក និងបុកស្រូវ។ មិនតែប៉ុណ្ណោះ ឡាំ ត្រូវទៅច្រូតស្រូវនៅសហករណ៍ផ្សេងទៀត។ នៅក្នុងទីតាំងដែល ឡាំ រស់នៅ ប្រជាជនប្រុស-ស្រីត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ដោយគ្មានពេលសម្រាក និងគ្មានអាហារហូបចុកគ្រប់គ្រាន់ទេ។ របបអាហារប្រចាំថ្ងៃមានតែបបរលាយជាមួយត្រកួន, មើមដំឡូង និងដើមចេក។[29]

*បទពិសោធន៍របស់អ្នករស់រានមានជីវិតនៃភូមិភាគពាយ័ព្យ (ភូមិភាគ៥៦០)*

**ឈួប ឈួន** មានអាយុ ៧៨ឆ្នាំ រស់នៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។ ឈួន ជាអតីតប្រធានកសិដ្ឋានមួយកន្លែង ដែលមានសមាជិកក្រុម ៦នាក់មកពីសហករណ៍ទួលអំពិល។ ឈួន ត្រូវបង្ខំឱ្យទៅធ្វើការដាំដុះដំណាំទាំងមានជំងឺប្រចាំកាយ ដើម្បីប្រមូលផលឱ្យបានសម្រេចតាមគោលដៅ ឬ ទៅតាមផែនការដែលខ្មែរក្រហមបានដាក់ចេញ។ ចំណែករបបអាហារហូបចុកប្រចាំថ្ងៃ គឺក្នុងម្នាក់ទទួលបានអង្ករមួយកំប៉ុង។ របបអាហារស្តួចស្តើងនេះ បណ្តាលឱ្យមនុស្សម្នាស្ទើរតែគ្មានកម្លាំងធ្វើការ។[30]

*បទពិសោធន៍របស់អ្នករស់រានមានជីវិតពីភូមិភាគបស្ចិម (ភូមិភាគ៤០១)*

---

[29] ស្រ៊ាង លីហ៊្សរ, (២០២៤) ,ក្រុមត្បាញកន្ទេល, សម្ភាសជាមួយ ផើវ ឡាំ ដោយ បេង ហង្ស នៅថ្ងៃទី១៥ ខែមករា ឆ្នាំ ២០២៤។ មជ្ឈមណ្ឌលឯកសារកម្ពុជា,ទាញយកនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/phaev-lam/

[30] ស្រ៊ាង លីហ៊្សរ, (២០២៣) , ពិតថាមិនពិត មិនពិតថាពិត, សម្ភាសជាមួយ ឈួប ឈួន ដោយ លឿប សុផៃលីន នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/chhoub-chhuon/



**ញឹក ឡូត** មានអាយុ ៧៣ឆ្នាំ រស់នៅភូមិបុសមាស ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ជាអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម បានរំឭកពីអតីតកាលនៅក្នុងភូមិភាគបស្ចិមថា នៅអាយុ ១៩ឆ្នាំ គ្រួសាររបស់ ឡូត ទាំងអស់ត្រូវបានបង្ខំឱ្យចាកចេញពីភូមិកំណើតទៅរស់នៅក្នុងសហករណ៍។ អំឡុងពេលធ្វើការនៅក្នុងកងចល័ត ឡូត ត្រូវធ្វើស្រែចម្ការ, ដាំដំឡូងមី និងជីកទំនប់។ របបអាហារសម្រាប់ការហូបចុក គឺមានតែបបរាវពីរពេលតែប៉ុណ្ណោះក្នុងមួយថ្ងៃ។ ក្រោយមក ឡូត ត្រូវបានទៅធ្វើការនៅខេត្តកោះកុង (ក្នុងភូមិភាគបស្ចិម) រហូតដល់ធ្លាក់ខ្លួនឈឺ។ ទោះបីជាយ៉ាងណា កម្មាភិបាលខ្មែរក្រហមមិនត្រឹមតែមិនព្យាបាលគាត់នោះទេ ថែមទាំងចោទប្រកាន់គាត់ថាមាន «ជំងឺសតិអារម្មណ៍»ទៀតផង។ ដូច្នេះគាត់ត្រូវតែបន្តធ្វើការងារទាំងមានជំងឺ។[31]

## *បទពិសោធន៍របស់អ្នករស់រានមានជីវិតពីភូមិភាគឦសាន (ភូមិភាគ១០៨)*

សម្រាប់ការហូបចុកនៅភូមិភាគឦសានក្នុងរបបខ្មែរក្រហម គឺមិនខុសគ្នាទៅនឹងភូមិភាគដទៃទៀតនោះទេ។ **ផេង សុខ** មានអាយុ ៧៤ឆ្នាំ បច្ចុប្បន្នរស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបូរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ នៅឆ្នាំ១៩៧៥ សុខ ត្រូវបានខ្មែរក្រហមបង្ខំឱ្យធ្វើការងាររួមនៅក្នុងកងចល័ត។ សុខ ត្រូវជីកទំនប់ គាស់គល់ឈើ និងប្រមូលលាមកមនុស្សសម្រាប់ធ្វើជីទាំងហេវហត់ និងអស់កម្លាំង។ ក្នុងមួយ

[31] ស្រ៊ាង លីហ៊្សរ, (២០២៣) , ជីវិតពោរពេញទៅដោយភាពជូរចត់, សម្ភាសជាមួយ ញឹក ឡូត ដោយ បឿន ស្រីនិច នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤។
https://thekrsurvivors.news/nhek-lot/

ថ្ងៃ សុខ ទទួលបានតែបបរាវលាយជាមួយចេក ពោត និងស្លឹកឈើតែប៉ុណ្ណោះសម្រាប់បរិភោគប្រចាំថ្ងៃនៅក្នុងសហករណ៍។[32]

***បទពិសោធន៍របស់អ្នករស់រានមានជីវិតពីតំបន់សៀមរាប-ឧត្តរមានជ័យ (តំបន់១០៦)***



**ជិញ ហៀ** មានអាយុ ៦៣ឆ្នាំ រស់នៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកវ៉ារិន ខេត្តសៀមរាប។ នៅពេលខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ហៀ ត្រូវបានចាត់ទុកជាប្រជាជនចាស់ បន្ទាប់មកចូលធ្វើការក្នុងកងចល័ត។ ជារៀងរាល់ថ្ងៃ ហៀ ត្រូវធ្វើពលកម្មទាំងហួសកម្លាំង និងហូបចុកមិនគ្រប់គ្រាន់។ លើសពីនេះ ហៀ ត្រូវរស់នៅ និងធ្វើការបែកពីសមាជិកគ្រួសារ។ អ្វីដែលគួរឱ្យសោកស្តាយជាងនេះទៅទៀត ប្រជាជននៅក្នុងតំបន់នោះ ត្រូវបានខ្មែរក្រហមចាប់ចងយកទៅសម្លាប់។[33]

[32] ស្រ៉ាង លីហ្សែរ, (២០២៤) , ការទម្លាក់គ្រាប់បែកក្នុងភូមិ, សម្ភាសជាមួយ ផេង សុខ ដោយ ស្រេង លីដា នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/pheng-sok/

[33] ហៀង នីតា, (២០២៤) , គេប្រើឱ្យរែកដីដោយមិនហ៊ានត្អូញត្អែរសូម្បីតែពាក្យមួយម៉ាត់, សម្ភាសជាមួយ ជិញ ហៀ ដោយ ហាំ សៀងហេង, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/chhih-heang/

*បទពិសោធន៍របស់អ្នករស់រានមានជីវិតពីតំបន់ព្រះវិហារ (តំបន់១០៣)*



**ធឹង ជូ** មានអាយុ ៨០ឆ្នាំ រស់នៅភូមិក្របៅ ឃុំគូលែនត្បូង ស្រុកគូលែន ខេត្តព្រះវិហារ។ ជូ ជាប្រធានក្រុមកងនារីនៅសម័យខ្មែរក្រហម។ នៅឆ្នាំ១៩៧៥ ជូ ត្រូវបានអង្គការចោទប្រកាន់ថាជាប្រពន្ធជនក្បត់ បន្ទាប់ពីប្តីរបស់គាត់បានរត់ភៀសខ្លួនទៅប្រទេសថៃ។ ជូ ត្រូវតស៊ូរស់នៅយ៉ាងលំបាក ក្នុងនាមជាស្ត្រីមេម៉ាយ និងត្រូវចិញ្ចឹមកូនតែម្នាក់ឯង។ ជារៀងរាល់ថ្ងៃ ជូ ត្រូវដឹកនាំកងនារីទៅច្រូតកាត់, ស្ទូងស្រូវ, ដាំដុះ, គាស់គល់ឈើ, ជីកប្រឡាយ និងសាងសង់ទំនប់ជាដើម។ ជួនកាល ជូ ត្រូវអង្គការតម្រូវឱ្យកាប់ឈើនៅតាមជួរភ្នំដងរែក។ ចំពោះការហូបចុកវិញ ជូ ទទួលបានត្រឹមតែបបររាវប៉ុណ្ណោះ។ នៅក្នុងកងនារីដែលគាត់រស់នៅ បើមានអ្នកដែលខុសសីលធម៌ ឬលួចមានទំនាក់ទំនង ខ្មែរក្រហមនឹងវាយដំបុគ្គលនោះរហូតដល់ស្លាប់។[34]

[34] ស្រ៊ាង លីហ្សឺរ, (២០២៤) , ខ្មែរក្រហមហៅខ្ញុំជាប្រពន្ធជនក្បត់, សម្ភាសជាមួយ ធឹង ជូ ដោយ ធួក សែល នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/choeng-chou/

*បទពិសោធន៍របស់អ្នករស់រានមានជីវិតពីក្រុងកំពង់សោម*



**គួង ថុល** មានអាយុ ៦៥ឆ្នាំ រស់នៅភូមិផ្សារជ្រៃ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលត្រូវបានជម្លៀសទៅក្រុងកំពង់សោម។ នៅអាយុ ១៩ឆ្នាំ ថុល ត្រូវបានខ្មែរក្រហមបញ្ជាឱ្យទៅជីកព្រែកប្រឡាយ និងដកស្ទូង នៅក្នុងខេត្តតាកែវ។ ក្រោយមក ខ្មែរក្រហមបានជម្លៀស ថុល ឱ្យទៅធ្វើការងារនៅការដ្ឋានស្រែអំបិល ដែលធ្វើជាអ្នកបុកអំបិលនៅទីនោះអស់រយៈពេលជាងមួយខែ។ មិនយូរប៉ុន្មាន ថុល ត្រូវបានអង្គការបញ្ជូនឱ្យទៅកាប់ឆ្ការព្រៃនៅកំពង់សោមអស់រយៈពេលជិតមួយឆ្នាំ។ នៅទីនោះ ខ្មែរក្រហមចែកបាយ ឬបបរមួយកូនធុងសម្រាប់មនុស្ស ៦នាក់ ហូបក្នុងមួយពេល ដោយមួយថ្ងៃទទួលបានពីរពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច។ ថុល បានរំឭកពីការហូបចុកមិនគ្រប់គ្រាន់ និងការឈឺថ្កាត់ដែលគ្មានថ្នាំសម្រាប់ព្យាបាលនាសម័យនោះទាំងស្រណោះ។ បន្ថែមពីនេះ ថុល និងប្រជាជនផ្សេងទៀតក៏ត្រូវបានខ្មែរក្រហមបង្ខំឱ្យរៀបការថែមទៀតផង។[35]

*បទពិសោធន៍របស់អ្នករស់រានមានជីវិតពីតំបន់ក្រចេះ (តំបន់៥០៥)*

**ប៊ូ មាយ** មានអាយុ ៨២ឆ្នាំ រស់នៅភូមិថ្មគ្រែ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ។ មាយ ត្រូវបានខ្មែរក្រហមយកទៅអប់រំនៅភ្នំត្រាំង ដោយសារខ្មែរក្រហមចោទថាប្តីរបស់គាត់ជាខ្មាំងរបស់អង្គការ។ ចំណែកប្តីរបស់គាត់ត្រូវបានអង្គការចាប់ខ្លួន និងបាត់ខ្លួនតាំងពីពេលនោះមក។ នៅភ្នំត្រាំង មាយ ត្រូវដកសំណាបគាស់គល់ឈើទាំងហួសកម្លាំង ហើយប្រសិនបើគាត់ធ្វើការងារមិនបានតាមការកំណត់របស់អង្គការនោះ

---

[35] នេន ស្រីមុំ, (២០២៤) , អង្គការនាំទៅទីណាត្រូវតែទៅ, សម្ភាសជាមួយ គួង ថុល ដោយ ផន ហេងលី នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០២៣, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/kuong-thol/

ទេ គាត់នឹងត្រូវស្តីបន្ទោស ឬយកទៅអប់រំម្តងទៀត។ ចំណែកពេទ្យនាសម័យនោះ គឺបានសិក្សារៀនសូត្រតែប៉ុន្មានខែប៉ុណ្ណោះ មុនពេលចេញព្យាបាលប្រជាជន។ ពេទ្យខ្មែរក្រហមបានព្យាបាលកូនរបស់គាត់ម្នាក់ទាល់តែពិការមកទល់សព្វថ្ងៃ។ ក្នុងសហករណ៍របស់គាត់ ទ្រព្យសម្បត្តិត្រូវបានប្រមូលដាក់ជាសមូហភាពទាំងអស់។ មាយ ត្រូវក្រោកពីព្រឹកម៉ោង៥ និងធ្វើការរហូតដល់យប់អជ្រាត្រ ដោយមានពេលសម្រាកតិចតួចបំផុត។ ដំណាំជុំវិញផ្ទះ ក៏ខ្មែរក្រហមមិនឱ្យបេះហូបដែរ ហើយប្រជាជនស្គមស្គាំងដោយសារខ្វះអាហារងាយនឹងកើតមានជំងឺផ្សេងៗ ថែមទាំងខិតខំធ្វើការទាំងអស់កម្លាំង។[36]

*បទពិសោធន៍របស់អ្នករស់រានមានជីវិតពីតំបន់មណ្ឌលគិរី (តំបន់១០៥)*

**ស្រូវ ភ្លើង** មានអាយុ ៦៤ឆ្នាំ រស់នៅភូមិពូក្រែង ឃុំស្រែអំពូម ស្រុកពេជ្រចិន្តា ខេត្តមណ្ឌលគិរី។ នៅអាយុ ១៥ឆ្នាំ ភ្លើង ត្រូវបានជម្លៀសឱ្យទៅរស់នៅ និងធ្វើជាកងចល័តស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ការងារនៅទីនោះមានដូចជា ធ្វើស្រែចម្ការ និងលើកទំនប់ប្រឡាយ ដោយចាប់ផ្តើមធ្វើការពីម៉ោង ៥ព្រឹកទៀបភ្លឺរហូតដល់យប់អជ្រាត្រទើបបានសម្រាក។ ឪពុករបស់ ភ្លើង បានបាត់ខ្លួន នៅពេលដែលខ្មែរក្រហមហៅទៅប្រជុំ ដោយត្រូវបានខ្មែរក្រហមចោទថាជាខ្មាំងដែលចូលដៃជាមួយកងទ័ពវៀតណាមដើម្បីផ្តួលរំលំរបបខ្មែរក្រហម។ នៅពេលខ្មែរក្រហមសួរគាត់ថា «ចង់ទៅតាមឪពុកទេ?» គាត់បានបដិសេធ។ បើឆ្លើយថាចង់ទៅតាមនោះ គាត់នឹងត្រូវខ្មែរក្រហមសម្លាប់ទាំងគ្រួសារ។ ចំណែកឯ របបអាហារនៅក្នុងតំបន់មណ្ឌលគិរីដែល ភ្លើង រស់នៅវិញ គឺមានបបរលាយជាមួយមើមក្តួច ឬមើមដំឡូង ហើយទទួលបានបីពេលក្នុងមួយថ្ងៃ។ ប្រជាជន ទទួលបានសម្លៀកបំពាក់ពីរសម្រាប់ក្នុងមួយឆ្នាំតែប៉ុណ្ណោះ។[37]

តាមរយៈសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យមកពីភូមិភាគ និងតំបន់ផ្សេងៗបានឱ្យដឹងថា ការហូបចុកមិនគ្រប់គ្រាន់ និងធ្វើការហួសកម្លាំង គឺកើតមានឡើងទូទាំងប្រទេសកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការសម្លាប់ ការហូបចុកមិនគ្រប់គ្រាន់ និងធ្វើការហួសកម្លាំង គឺជាមូលហេតុដែលនាំឱ្យប្រជាជនជាង ២លាន បានបាត់បង់ជីវិត។

## ការកេម្ទចកម្មាភិបាលខ្មែរក្រហមក្នុងភូមិភាគបូព៌ា

ឆ្លងតាមរយៈការអាន និងសរសេរសាច់រឿងចេញពីបទសម្ភាសជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្រុមការងារ ឌីញូស៍ ក៏បានចាប់អារម្មណ៍នឹងចង់រំលេចនូវព្រឹត្តិការណ៍គួរជាទីកត់សម្គាល់មួយដែលបានកើតមាននៅក្នុងភូមិភាគបូព៌ា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

---

[36] នេន ស្រីមុំ, (២០២៤), អតីតអ្នកទោសនៅក្នុងរបបខ្មែរក្រហម, សម្ភាសជាមួយ បូ មាយ ដោយ យ៉ុង ផល្លីន នៅថ្ងៃទី២៥ ខែមករា ឆ្នាំ ២០២៤, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/bo-meak/

[37] ធី ស្រីពេជ្រ, (២០២៤), ឪពុកស្លាប់ដោយសារអង្គការចោទថាក្បត់, សម្ភាសជាមួយ ស្រូវ ភ្លើង ដោយ ធី ស្រីពេជ្រ នៅខែវិច្ឆិកា ឆ្នាំ២០២៤, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទាញយកនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤។ https://thekrsurvivors.news/srov-ploeung/

ការប៉ះទង្គិចជាមួយវៀតណាមក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ បាននាំទៅដល់ការធ្វើបន្សុទ្ធកម្មទ្រង់ទ្រាយធំមួយ។ នៅចុងឆ្នាំ១៩៧៧ បន្ទាប់ពី ប៉ុល ពត វិលត្រលប់មកពីប្រទេសចិនវិញ កងទ័ពវៀតណាម បានវាយចូលប្រទេសកម្ពុជាភាគបូព៌ា។ បីទៅបួនខែក្រោយមក កងទ័ពវៀតណាមបានដកថយទៅវិញ ដោយបានកៀរយកប្រជាជនកម្ពុជារាប់រយនាក់ទៅជាមួយផង។ បន្ទាប់មកខ្មែរក្រហម បានចោទប្រជាជន និងកម្មាភិបាលភូមិភាគបូព៌ាថា បានចូលដៃចូលជើងជាមួយវៀតណាម។ ហេតុការណ៍នេះ បានជំរុញឱ្យមានការចាប់ខ្លួន និងការសម្លាប់មនុស្សជាច្រើននាក់ រួមទាំងអ្នកដែលស្មោះត្រង់នឹងខ្មែរក្រហម និងដៃគូនយោបាយជើងចាស់ដ៏យូរលង់ដូចជា សោ ភឹម ទៀតផង។[38]

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពាក្យ «កម្ទេច»មានន័យថា «បោសសម្អាត ឬសម្លាប់»។ ជនណាដែលត្រូវបានសង្ស័យក្នុងការធ្វើសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋ ប្រជាជន ត្រូវបានចាត់ទុកថាជា «ខ្មាំង» ដែលត្រូវតែ «កម្ទេច» រីឯជនដែលបានប្រព្រឹត្តក្រៅប្រភេទខាងលើចាត់ទុកជា «សមាសភាពមិនល្អ» ត្រូវអប់រំកែសាងក្នុងក្របខណ្ឌអង្គការរដ្ឋ ឬក្នុងក្របខណ្ឌអង្គការប្រជាជន។ «ការបោសសម្អាត» មានន័យថា ធ្វើឱ្យបរិសុទ្ធផ្នែកគោលនយោបាយតាមរយៈការដាក់ទណ្ឌកម្មដែលមានចាប់ពីការបញ្ចុះឋានន្តរសក្តិបុគ្គលណាម្នាក់រហូតដល់យកទៅលត់ដំ ឬរហូតដល់កម្រិតធ្ងន់ធ្ងរគឺ «កម្ទេច»។[39] ក្រៅពីការចោទប្រកាន់ខាងលើ មេដឹកនាំបក្សកុម្មុនីស្តកម្ពុជា តែងតែភ្ជាប់អ្នកដែលត្រូវ «កម្ទេច ឬសម្លាប់» ទៅនឹងការចោទប្រកាន់ថា ជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ សេ.អ៊ី.អា អាមេរិក និងភ្នាក់ងារស៊ើបការណ៍ កា.ហ្សេ.បេ សូវៀត ជាដើម។

បន្ទាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលបដិវត្តន៍ខ្មែរក្រហម ឬបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ទទួលបានជ័យជម្នះទាំងស្រុងលើរបប លន់ នល់ ខ្មែរក្រហមបានប្តូរឈ្មោះប្រទេសកម្ពុជាពី របបសាធារណរដ្ឋខ្មែរទៅជា របបកម្ពុជាប្រជាធិបតេយ្យ។ របបកម្ពុជាប្រជាធិបតេយ្យ បានគ្រប់គ្រងប្រទេសកម្ពុជាពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩។ របបនេះដឹកនាំដោយ ប.ក.ក ដែលមាន ប៉ុល ពត ជាលេខា និង នួន ជា ជាអនុលេខា។ ប.ក.ក ដឹកនាំដោយគណៈមជ្ឈិមបក្សដែលជាអង្គការតែមួយគត់ដែលមានសិទ្ធិអំណាចសម្រេចរាល់សេចក្តីសម្រេចចិត្តសំខាន់ៗទាំងអស់។ ក្រៅពីគណៈមជ្ឈិមបក្ស លេខាបក្សប្រចាំភូមិភាគក៏ជាមនុស្សដែលមានអំណាចខ្លាំងដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

---

[38] ផេង ពង្សរ៉ាស៊ី et al, (២០២០) , *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)* , បោះពុម្ពលើកទី២, ភ្នំពេញ, មជ្ឈមណ្ឌលឯកសារកម្ពុជា, ទំព័រទី៤៨។

[៣៩] នេះបើយោងតាមរដ្ឋធម្មនុញ្ញរបស់របបកម្ពុជាប្រជាធិបតេយ្យថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ជំពូកទី៧នៃមាត្រា១០។

ទស្សនាវដ្ដីទង់បដិវត្តន៍ចេញផ្សាយខែកក្កដា ឆ្នាំ១៩៧៨ បានជម្រុញឱ្យសមាជិក ប.ក.ក ឱ្យបន្តបំផុសចលនាមហាជនឱ្យបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងតទៅទៀតឱ្យបានខ្លាំងក្លាជាប់ជានិច្ច។ ខែកញ្ញា ឆ្នាំ១៩៧៨ ប៉ុល ពត បានផ្សព្វផ្សាយគោលនយោបាយថ្មីនេះនៅកិច្ចប្រជុំធំមួយជាមួយកម្មាភិបាលបក្សនៅទូទាំងផ្ទៃប្រទេស។ នៅក្នុងការប្រជុំជាផ្លូវការរបស់ ប.ក.ក នាខែកក្កដា ឆ្នាំ១៩៧៥ ប្រធាននៃគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្សបានប្រកាសថា កងទ័ពបដិវត្តន៍ ត្រូវការពារប្រទេសប្រឆាំងនឹង « ខ្មាំងស៊ីរូងផ្ទៃក្នុង» និងថា កាតព្វកិច្ចកងទ័ពបដិវត្តន៍គឺ «បន្តការកម្ទេច» ។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបានរាយការណ៍អំពីការកម្ទេចក្នុងជួរ និងក្រៅជួរថា ត្រូវអនុវត្តដូចខាងក្រោម៖ បើនៅក្នុងក្របខណ្ឌមូលដ្ឋានត្រូវគណៈអចិន្ត្រៃយ៍ភូមិភាគសម្រេច។ នៅជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ នៅតំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច។ នៅកងទ័ពមជ្ឈិមត្រូវសេនាធិការ សម្រេច។[40]

យោងតាមរដ្ឋធម្មនុញ្ញរបបខ្មែរក្រហមដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ បានកំណត់ថា សភាតំណាងប្រជាជនបដិវត្តន៍កម្ពុជា គឺជាអំណាចនីតិបញ្ញត្តិនៃកម្ពុជាប្រជាធិបតេយ្យ។ សមាជិកសភាដែលមានសមាជិក ២៥០រូប (១៥០រូប តំណាងកសិករ, ៥០រូបតំណាងកម្មករ និងពលករផ្សេងទៀត, និង ៥០រូបតំណាងកងទ័ពបដិវត្តន៍)។ រដ្ឋធម្មនុញ្ញមិនមានចែងអ្វីទាំងអស់ទាក់ទងនឹង ប.ក.ក ហើយរដ្ឋសភាបានបើកសម័យប្រជុំតែម្តងគត់នៅខែមេសា ឆ្នាំ១៩៧៦។[41] សមាជិកសភា ត្រូវជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយផ្ទាល់ និងជាសម្ងាត់សម្រាប់អណត្តិ៥ឆ្នាំ។ បើទោះជារបបកម្ពុជាប្រជាធិបតេយ្យមានរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ ប.ក.ក ក្តី ក៏មេដឹកនាំរបបនេះមិនដែលយកចិត្តទុកដាក់គោរពតាមនោះឡើយ។

### *រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ និង ប.ក.ក*

*រចនាសម្ព័ន្ធការគ្រប់គ្រងរដ្ឋ៖* ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ, នួន ជា ជាប្រធានសភាតំណាងប្រជាជនបដិវត្តន៍កម្ពុជា និង, ប៉ុល ពត ជានាយករដ្ឋមន្ត្រី។[42] ក្រសួងនានារួមមាន៖ ក្រសួងការបរទេសដឹកនាំដោយ អៀង សារី, ក្រសួងសេដ្ឋកិច្ច ដឹកនាំដោយ វន វ៉េត, ក្រសួងការពារជាតិដឹកនាំដោយ សុន សេន, ក្រសួងឧស្សាហកម្មដឹកនាំដោយ ចេង អន, ក្រសួងឃោសនាការ និងព័ត៌មានដឹកនាំដោយ ហ៊ូ នឹម, ក្រសួងសង្គមកិច្ចដឹកនាំដោយ អៀង ធីរិទ្ធិ (ប្រពន្ធរបស់ អៀង សារី), ក្រសួងវប្បធម៌ និងអប់រំ ដឹកនាំ

---

[40]ឯកសារលេខD427 (១៥ ខែកញ្ញា ឆ្នាំ២០១០) ដីកាដំណោះស្រាយសំណុំរឿង ០០២ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ទំព័រទី៥៨-៥៩។

[41]ផេង ពង្សរ៉ាស៊ី et al. ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩), មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០២០, ភ្នំពេញ, បោះពុម្ពលើកទី២, ទំព័រទី៣០។

[42]ផេង ពង្សរ៉ាស៊ី et al. ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩), មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០២០, ភ្នំពេញ, បោះពុម្ពលើកទី២, ទំព័រទី៣១-៣២។

ដោយ យុន យ៉ាត (ប្រពន្ធរបស់ សុន សេន), ក្រសួងសុខាភិបាលដឹកនាំដោយ ជួន ជឿន, ក្រសួងយុត្តិធម៌ ដឹកនាំដោយ កង ចាប, ក្រសួងកសិកម្មដឹកនាំដោយ នន សួន, ក្រសួងពាណិជ្ជកម្ម ដឹកនាំដោយ កុយ ធួន , និងក្រសួងសាធារណការ ដឹកនាំដោយ តូច ភឿន។

*ប.ក.ក* ចែកចេញជាពីរ គឺគណៈអចិន្ត្រៃយ៍ ប.ក.ក និងគណៈមជ្ឈិម ប.ក.ក។ គណៈអចិន្ត្រៃយ៍ ប.ក.ក មានសមាជិក ៥រូប៖ ប៉ុល ពត លេខាបក្ស, នួន ជា អនុលេខាបក្ស, អៀង សារី, សោ ភឹម, និងវន វ៉េត, សមាជិក និង គណៈមជ្ឈិម ប.ក.ក មានសមាជិក១០រូប៖ ប៉ុល ពត, នួន ជា, អៀង សារី, សោ ភឹម, វន វ៉េត, សុន សេន, ឈិត ជឿន ហៅម៉ុក, ខៀវ សំផន, ញឹម រស់, និងកែ ពក។

## *រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋាន*

នៅថ្នាក់មូលដ្ឋានរបបខ្មែរក្រហមបានបែងចែករចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលទៅជាតំបន់ស្វយ័ត, ភូមិភាគ, តំបន់, ស្រុក, ឃុំ, និងសហករណ៍។ តំបន់ស្វយ័ត, ភូមិភាគ, តំបន់, ស្រុក, ឃុំ, និងសហករណ៍, ដឹកនាំដោយគណៈ ដែលគណៈនីមួយៗត្រូវដឹកនាំដោយលេខាជាប្រធាន និងអនុលេខាជាអនុប្រធាន និង មានភារកិច្ចរាយការណ៍ដោយផ្ទាល់ទៅគណៈមជ្ឈិម ប.ក.ក។ លេខាភូមិភាគត្រូវបានតែងតាំងជាទូទៅ ដោយគណៈមជ្ឈិម ប.ក.ក។[43] ការអនុវត្តសេចក្តីសម្រេចរបស់គណៈមជ្ឈិម ប.ក.ក និងគណៈអចិន្ត្រៃយ៍ ប.ក.ក ត្រូវបានធ្វើឡើងដោយលេខាភូមិភាគ និងលេខាតំបន់ស្វយ័ត។ គោលនយោបាយ និងសេចក្តីណែនាំរបស់គណៈមជ្ឈិម ប.ក.ក និងគណៈអចិន្ត្រៃយ៍ ប.ក.ក ត្រូវបានផ្សព្វផ្សាយដល់លេខាភូមិភាគ និង លេខាតំបន់ស្វយ័ត ដែលនឹងផ្សព្វផ្សាយគោលនយោបាយ និងសេចក្តីណែនាំទាំងនោះបន្តទៀតក្នុង ចំណោមលេខាតំបន់ និងលេខាស្រុក ដើម្បីអនុវត្ត។ ផ្ទុយទៅវិញ ឃុំនានាបានរាយការណ៍ត្រលប់ទៅគណៈ ស្រុកវិញដែលគណៈស្រុកត្រូវរាយការណ៍បន្តទៅគណៈតំបន់ដែលគណៈតំបន់ត្រូវរាយការណ៍បន្តទៅគ ណៈភូមិភាគ។

ភូមិភាគត្រូវបានបែងចែកជា ៦ រួមមាន ភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ ភូមិភាគឦសាន ភូមិភាគ និរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ក្នុងនោះមាន ៣២តំបន់។ បន្ថែមដោយតំបន់ស្វយ័តចំនួន ៥ ត្រូវ បានបង្កើតរួមមាន៖ តំបន់ស្វយ័ត ១០៣ព្រះវិហារ, តំបន់ស្វយ័ត ១០៥មណ្ឌលគិរី, តំបន់ស្វយ័ត ១០៦ សៀមរាប, តំបន់ស្វយ័ត ៥០៥ក្រចេះ, តំបន់ស្វយ័តក្រុងកំពង់សោម។[44]

*ភូមិភាគបូព៌ា* (ភូមិភាគ២០៣) ដឹកនាំដោយ សោ ភឹម ដែលបានធ្វើអត្តឃាតនៅខែឧសភា ឆ្នាំ ១៩៧៨។ ភូមិភាគនេះ រួមមាន ខេត្តព្រៃវែង និងខេត្តស្វាយរៀងទាំងមូល ហើយផ្នែកខ្លះនៃខេត្តកំពង់ចាម

---

[43]ឯកសារលេខD427 (១៥ ខែកញ្ញា ឆ្នាំ២០១០) ដីកាដំណោះស្រាយសំណុំរឿង ០០២ របស់ការិយាល័យសហចៅក្រមស៊ើប អង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ទំព័រទី២៤។

[44]ផេង ពង្សរ៉ាស៊ី et al, ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០២០, ភ្នំពេញ, បោះពុម្ពលើកទី២, ទំព័រទី៣៣-៣៥។

ដែលស្ថិតនៅត្រើយខាងកើតទន្លេមេគង្គទាំងអស់កាត់ចេញពីស្រុកមួយក្នុងខេត្តក្រចេះ គឺស្រុកឆ្លូង និង កាត់យកស្រុកខ្លះពីខេត្តកណ្ដាលដែលមានស្រុកខ្សាច់កណ្ដាល ស្រុកល្វាឯម និងស្រុកមុខកំពូល។ ភូមិភាគនេះចែកចេញជា ៥តំបន់ រួមមាន តំបន់២០ តំបន់២១ តំបន់២២ តំបន់២៣ និងតំបន់២៤។

*ភូមិភាគនិរតី* (ភូមិភាគ៤០៥) ដឹកនាំដោយ ឈិត ជឿន ហៅតាម៉ុក។ ភូមិភាគនេះរួមមាន ខេត្តកំពត និងខេត្តតាកែវទាំងមូល ស្រុក២ក្នុងខេត្តកំពង់ស្ពឺ គឺស្រុកសំរោងទង និងស្រុកគងពិសី និងស្រុក៥ក្នុងខេត្តកណ្ដាល គឺស្រុកកណ្ដាលស្ទឹង ស្រុកស្អាង ស្រុកកោះធំ ស្រុកកៀនស្វាយ និងស្រុកលើកដែក។ ភូមិភាគនេះចែកចេញជា ៤តំបន់គឺ តំបន់១៣ តំបន់៣៣ តំបន់៣៥ និងតំបន់២៥។

*ភូមិភាគឧត្តរ* (ភូមិភាគ៣០៣) ដឹកនាំដោយ កុយ ធួន ហៅ ធុច ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៦។ បន្ទាប់ពី កុយ ធួន ត្រូវបានចាប់ខ្លួន និងសម្លាប់នៅគុកទួលស្លែងក្នុងឆ្នាំ១៩៧៦ កែ ពក ត្រូវចាត់តាំងជាលេខាភូមិភាគជំនួសវិញរហូតដល់ឆ្នាំ១៩៧៧ ទើប កែ ពក ត្រូវបានចាត់តាំងឱ្យធ្វើជាលេខាភូមិភាគកណ្ដាលដែលទើបបង្កើតថ្មី ហើយលេខាថ្មីរបស់ភូមិឧត្តរគឺ កង ចាប។ ភូមិភាគនេះរួមមាន ខេត្តកំពង់ធំទាំងមូល ផ្នែកខាងស្ដាំទន្លេមេគង្គទាំងអស់នៃខេត្តកំពង់ចាម និងស្រុកមួយក្នុងខេត្តក្រចេះ (ស្រុកព្រែកប្រសប់) ហើយចែកចេញជា ៣តំបន់ តំបន់៤១ តំបន់៤២ និងតំបន់៤៣។

*ភូមិភាគពាយ័ព្យ* (ភូមិភាគ៥៦០) ដឹកនាំដោយ រស់ ញឹម ភូមិភាគនេះ រួមមាន ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងទាំងមូល ដែលចែកចេញជា ៧តំបន់គឺ តំបន់១ តំបន់២ តំបន់៣ តំបន់៤ តំបន់៥ តំបន់៦ និងតំបន់៧។

*ភូមិភាគបស្ចិម* (ភូមិភាគ៤០១) ដឹកនាំដោយ ជូ ជេត។ ភូមិភាគនេះ រួមមាន ខេត្តកោះកុង និងខេត្តកំពង់ឆ្នាំងទាំងមូល និងផ្នែកខ្លះនៃខេត្តកំពង់ស្ពឺ ហើយចែកចេញជា ៥តំបន់ គឺតំបន់៣១ តំបន់៣២ តំបន់៣៧ តំបន់១៥ និងតំបន់១១ ។

*ភូមិភាគឦសាន* (ភូមិភាគ១០៨) ដឹកនាំដោយ ណៃ សារ៉ាន់ ហៅ យ៉ា (សម្លាប់នៅឆ្នាំ១៩៧៦) ។ ភូមិភាគនេះ រួមមាន ខេត្តរតនគិរី ខេត្តមណ្ឌលគិរីទាំងមូល ផ្នែកខ្លះនៃខេត្តក្រចេះ និងផ្នែកខ្លះនៃខេត្តស្ទឹងត្រែងដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ។ ភូមិភាគនេះចែកចេញជា ៦តំបន់គឺ តំបន់១០១ តំបន់១០២ តំបន់១០៤ តំបន់១០៥ តំបន់១០៧ និងតំបន់៥០៥។

នៅឆ្នាំ១៩៧៧ ភូមិភាគថ្មីមួយទៀត គឺភូមិភាគកណ្ដាលត្រូវបានបង្កើតឡើង។ ភូមិភាគនេះមានទីតាំងស្ថិតនៅត្រង់អតីតភូមិភាគឧត្តរ ចំណែកភូមិភាគឧត្តរថ្មី ត្រូវបានប្ដូរទីតាំងទៅតំបន់សៀមរាប-ឧត្តរមានជ័យ និងតំបន់ព្រះវិហារ។ តំបន់៥០៥ក្រចេះ និងតំបន់១០៥ មណ្ឌលគិរី ត្រូវបានបំបែកចេញពីភូមិភាគឦសាន និងចាត់តាំងជាតំបន់ស្វយ័ត។

របបខ្មែរក្រហមដែលបានកាន់កាប់ប្រទេសកម្ពុជារយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ មេដឹកនាំរបបនេះបានកម្ទេចកម្មាភិបាលខ្លួនឯង និងសម្លាប់ប្រជាជនដោយចោទប្រកាន់ថា ជាភ្នាក់ងារសម្ងាត់ក្បត់ សេ.

អ៊ី.អា និង កា.ហ្សេ.បេ និងចូលដៃជើងជាមួយប្រទេសវៀតណាមជាដើម។ ការកម្ទេច ឬបោសសម្អាតនៅក្នុងរបបខ្មែរក្រហមធ្វើឡើងស្ទើរតែគ្រប់ភូមិភាគ និងតំបន់នៅទូទាំងប្រទេសកម្ពុជា។

*ខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅរបស់អង្គការខ្មែរក្រហម*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃជ័យជម្នះធំមួយរបស់ខ្មែរក្រហម ក្នុងការគ្រប់គ្រងប្រទេសកម្ពុជា។ ជ័យជម្នះនេះ គឺបង្ហាញពីការបញ្ចប់សង្គ្រាមស៊ីវិលរវាងខ្មែរ និងខ្មែរ នៅក្នុងប្រទេស។ ប្រជាជនភាគច្រើនគិតថា ប្រទេសកម្ពុជា នឹងត្រលប់ទៅរកសន្តិភាព សុខសុវត្ថិភាព ដូចកាលពីរបបសង្គមរាស្ត្រនិយម ផ្ទុយទៅវិញ គឺជាការចាប់ផ្តើមអំណាចឃោរឃៅមួយប៉ុណ្ណោះ។ យោធាខ្មែរក្រហម ដែលស្លៀកពាក់ពណ៌ខ្មៅ និងពណ៌អាចម៍សេះ បានជម្លៀសប្រជាជនទាំងអស់ឱ្យចេញពីទីក្រុងភ្នំពេញ។ បើតាមការលើកឡើងរបស់ ប៉ុល ពត ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺដើម្បីបំបែកក្រុមចារកិច្ចរបស់ខ្មាំង។

**ខ្មាំងរបស់អង្គការ** គឺសំដៅទៅលើអ្នកធ្វើការងារឱ្យរដ្ឋាភិបាល លន់ នល់ ហើយជាពិសេស គឺជាមន្ត្រីរាជការ និងទាហាន។ ទាហាន លន់ នល់ ជាច្រើននាក់ត្រូវបានបាញ់សម្លាប់ភ្លាមៗ នៅទីក្រុងភ្នំពេញ និងតាមផ្លូវជាតិផ្សេងៗ។ ចំពោះ ទាហាន លន់ នល់ មួយចំនួនទៀត ដែលបានលាក់ប្រវត្តិ ហើយបានធ្វើដំណើរទៅកាន់ស្រុកកំណើត ក៏ត្រូវបានអង្គការស៊ើបអង្កេត និងយកទៅសម្លាប់ចោលជាបន្តបន្ទាប់។ ជាក់ស្តែងទីតាំងសម្លាប់ធំមួយដែលមានឈ្មោះថា ទួលពោធិ៍ជ្រៃ ខេត្តពោធិ៍សាត់ គឺជាទីតាំងសម្លាប់ទាហាន លន់ នល់ រាប់ពាន់នាក់។

លោក **អ៊ុង ឆាត** អតីតទាហានខ្មែរក្រហម និងជាសាក្សីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង ០០២ បានផ្តល់សក្ខីកម្មអំពីអ្វីដែលលោកបានឃើញ និងឮខណៈពេលលោករស់នៅតំបន់ទួលពោធិ៍ជ្រៃក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៥។ លោក អ៊ុង ឆាត បានពិពណ៌នាថា បានជួបជាមួយនឹងទាហាន លន់ នល់ នៅឯបន្ទាយភូមិពោធិ៍៖ «អង្គការអនុញ្ញាតឱ្យរថយន្តបរទៅកាន់ទីនោះម្តងមួយប៉ុណ្ណោះ។ ខ្ញុំបានឃើញយោធាខ្មែរក្រហមរាប់រយនាក់ឡោមព័ទ្ធទាហាន លន់ នល់ ទាំងអស់នោះ។ ខ្មែរក្រហមបានតាំងទីត្រួតពិនិត្យនៅចំទីតាំង និងហាមឃាត់ប្រជាជនពីការធ្វើដំណើរទៅកាន់តំបន់នោះ។ ខ្ញុំត្រូវបានបង្អាក់ និងសាកសួរដោយទាហានខ្មែរក្រហម ក៏ប៉ុន្តែដោយសារតែខ្ញុំមានលិខិតអនុញ្ញាត គេអនុញ្ញាតឱ្យខ្ញុំចូលទៅ។ នៅពេលខ្ញុំនៅទីនោះ ខ្ញុំបានឃើញខ្មែរក្រហម បើកផ្លូវឱ្យរថយន្តបរចេញពីទីនោះម្តងមួយៗ រៀងរាល់រយៈពេល ២០នាទី។ ខ្មែរក្រហមមិនអនុញ្ញាតឱ្យរថយន្តបន្ទាប់ដែលផ្ទុកដោយទាហាន លន់ នល់ ចេញទៅកាន់ទួលពោធិ៍ជ្រៃទេ លុះត្រាតែគេឃើញរថយន្តដែលបរចេញទៅមុខត្រលប់មកវិញដោយទទេ»។ ក្រោយមកលោក អ៊ុង ឆាត បានទៅទីនោះជាមួយអ្នកភូមិពីរនាក់ ដើម្បីទៅមើលសាកសពនៅក្នុងបន្ទាយទួលពោធិ៍ជ្រៃ។ លោកបានរាយការណ៍ថា សាកសពរបស់ទាហានទាំងអស់ គ្រៀបគ្រានៅលើដី ដោយក្បាលនៃសាកសពនោះដាក់សំដៅទៅកាន់ទិសខាងជើង និងស្លៀកពាក់ស៊ីវិល ជាជាងឯកសណ្ឋាន

យោធា។ សាកសពទាំងអស់នោះត្រូវបានចងភ្ជាប់គ្នាដោយខ្សែជាក្រុមពី១៥ ទៅ២០សាកសពក្នុងមួយក្រុម ហើយដៃទាំងពីរត្រូវបានចងទៅក្រោយ។

ក្នុងពេលជាមួយគ្នាដែរ ដើម្បីធ្វើឱ្យបដិវត្តន៍របស់ខ្លួនស្អាតស្អំ និងរីកចម្រើន មហាលោតផ្លោះ និងមហាអស្ចារ្យ ខ្មែរក្រហមបានការពារបក្សរបស់ខ្លួនពី «*ខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ*» ដែលកើតចេញមកពីការមិនទុកចិត្តគ្នា និងការធ្វើបន្សុទ្ធកម្ម។ *ខ្មាំងខាងក្នុង* របស់អង្គការ មានដូចជា មន្ត្រីរដ្ឋការ ឬទាហានលន់ នល់, ប្រជាជនថ្មី, ជនជាតិភាគតិច, ជនជាតិវៀតណាម ជនជាតិចាម និងជនជាតិចិន មួយចំនួនរួមជាមួយអ្នកមានទ្រព្យសម្បត្តិ ឬក៏បញ្ញវន្ត។ ចំពោះប្រជាជនរូបណាដែលចេញពីគ្រួសារកសិករក្រីក្រ ហើយបានចូលរួមបដិវត្តន៍ អង្គការបានផ្តល់សិទ្ធិឱ្យអ្នកទាំងនោះគ្រប់គ្រង និងតាមដានខ្មាំងរបស់ខ្លួន។ ខ្មាំងរបស់អង្គការទាំងអស់ គឺជាមុខសញ្ញា ដែលត្រូវយកទៅសម្លាប់ចោលនៅពេលដែលអ្នកទាំងអស់នោះប្រព្រឹត្តកំហុសតិចតួច ឬក៏មានការរអ៊ូអំពីការងារលំបាក និងការហូបអាហារជាដើម។ ខាងក្រោមនេះ គឺជាការបោសសម្អាតខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅរបស់អង្គការខ្មែរក្រហម។

### *ខ្មាំងខាងក្នុង*

បើក្រឡេកមើលទៅអតីតកាល ប្រជាជនជាច្រើន រួមទាំងមេដឹកនាំខ្មែរក្រហម ជឿជាក់ថាជនជាតិភាគតិច គឺជាជនជាតិមួយស្មោះត្រង់។ មុនពេលខ្មែរក្រហមឡើងកាន់អំណាច មេដឹកនាំខ្មែរក្រហមភាគច្រើនធ្លាប់បានរស់នៅក្នុងចំណោមជនជាតិភាគតិចតំបន់ភ្នំក្នុង ភូមិភាគឦសាន។ ភូមិភាគឦសាន គឺជាភូមិភាគមួយគ្រប់គ្រងដោយខ្មែរក្រហមតាំងពីឆ្នាំ១៩៧០មក។ ប៉ុន្តែ បើទោះបីជារបបនេះបានអះអាងថាស្រលាញ់ស្មោះស្ម័គ្រ និងជឿទុកចិត្តលើជនជាតិតំបន់ភ្នំយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមចាប់ផ្តើមធ្វើការផ្លាស់ទីលំនៅជនជាតិភាគតិចក្នុងខេត្តមណ្ឌលគីរី ឱ្យទៅរស់នៅផ្តុំគ្នាក្នុងស្រុកកោះញែកនៅដើមឆ្នាំ១៩៧២ ដែលបណ្តាលឱ្យប្រជាជនស្លាប់ជាច្រើន។ ហេតុផលនៃការជម្លៀសប្រជាជននេះ ខ្មែរក្រហមបានលើកឡើងថា ដើម្បីធ្វើកសិកម្ម ព្រោះតំបន់ដែលជនជាតិភាគតិចរស់នៅភាគច្រើន គឺសម្បូរទៅដោយព្រៃឈើ។ ការជម្លៀសជនជាតិភាគតិចតំបន់ភ្នំនេះ គឺមិនមែនធ្វើឡើងដោយស្ម័គ្រចិត្តនោះទេ ប្រសិនបើមានអ្នកជំទាស់ នឹងត្រូវយកទៅសម្លាប់ចោល។ ការសម្លាប់ជនជាតិភាគតិចតំបន់ភ្នំនេះ អង្គការបានចោទប្រកាន់ថា រត់ចូលទៅដីវៀតណាម ហើយសហការណ៍ជាមួយវៀតណាមដើម្បីផ្តួលរំលំបដិវត្តន៍។

**ស្រូវ ភ្លើង** ភេទស្រី បានរៀបរាប់អំពីការសម្លាប់ឪពុករបស់គាត់នៅស្រុកកោះញែក ខេត្តមណ្ឌលគិរី។ នៅក្នុងសម័យខ្មែរក្រហម ភ្លើង មានអាយុ១៥ឆ្នាំ។ គ្រួសាររបស់ ភ្លើង ត្រូវបានអង្គការជម្លៀសចេញពីភូមិពូក្រែង ឃុំស្រែអំពូល ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ទៅស្រុកកោះញែក។ នៅកោះញែក អង្គការបានចោទឪពុករបស់គាត់ថាជាខ្មាំងចូលដៃជាមួយវៀតណាមដើម្បីផ្តួលរំលំរបបខ្មែរក្រហម។ ឪពុករបស់ ភ្លើង ត្រូវបានអង្គការហៅទៅប្រជុំ និងបាត់ដំណឹងរហូតដល់បច្ចុប្បន្ន។ ក្រោយពីចាប់ឪពុកយកទៅបាត់ អង្គការបាន

មកសួរនាំសមាជិកក្រុមគ្រួសារបន្ថែមទៀត ថាចង់ទៅតាមឪពុកដែរឬទេ។ ភ្លើង និយាយថា ប្រសិនបើគាត់ឆ្លើយថាចង់ទៅតាមឪពុក អង្គការនឹងយកគាត់ និងគ្រួសារទៅសម្លាប់ជាក់ជាមិនខាន។[45]

បន្ទាប់ពីទទួលបានជ័យជម្នះ ខែមេសា ឆ្នាំ១៩៧៥ ប៉ុល ពត បានចេញជាគោលនយោបាយ ៨ ចំណុច ហើយ ២ចំណុចចុងក្រោយ គឺជាបញ្ញត្តិឱ្យធ្វើការបណ្តេញអាណិកជនវៀតណាមទាំងអស់ចេញពីប្រទេសកម្ពុជា និងការបញ្ជូនកងទ័ពទៅកាន់ព្រំដែន ជាពិសេសព្រំដែនវៀតណាម។ ជនជាតិវៀតណាមជាច្រើននាក់ត្រូវបានជម្លៀសចេញពីកន្លែងស្នាក់អាស្រ័យរបស់ខ្លួនក្នុងប្រទេសកម្ពុជា ត្រលប់ទៅរស់នៅប្រទេសវៀតណាមវិញ។ បើទោះបីជាយ៉ាងណា មានជនជាតិវៀតណាម ដែលមានប្តី ឬក៏ប្រពន្ធខ្មែរ មិនព្រមវិលត្រលប់ទៅវិញនោះទេ។ នៅឆ្នាំ១៩៧៧ បន្ទាប់ពីកាត់ផ្តាច់ទំនាក់ទំនងការទូតទាំងស្រុងជាមួយប្រទេសវៀតណាម ជនជាតិវៀតណាមទាំងអស់ដែលបន្តស្នាក់នៅក្នុងប្រទេស ទទួលរងនូវការសម្លាប់យ៉ាងសកម្ម រួមទាំងកូនចៅរបស់ខ្លួនដែលបានកើតនៅក្នុងប្រទេសកម្ពុជា។

ចំពោះការប្រព្រឹត្តិរបស់កម្មាភិបាលទៅលើជនជាតិចាម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមមានភាពខុសប្លែកគ្នាទៅតាមតំបន់។ នៅក្នុងឆ្នាំដែលអង្គការគ្រប់គ្រង កម្មាភិបាលខ្មែរក្រហមបានបង្ខំឱ្យជនជាតិចាមលុបបំបាត់ការគោរពសាសនា បង្ខំឱ្យហូបសាច់ជ្រូក និងធ្វើទុក្ខបុកម្នេញជាច្រើនទៀត។ ការធ្វើទារុណកម្មនេះហើយបានធ្វើឱ្យជនជាតិចាមមួយចំនួនងើបឡើងតស៊ូប្រឆាំងជាមួយបដិវត្តន៍។ ជាក់ស្តែង នៅក្នុងស្រុកក្រូចឆ្មារមានការតវ៉ាប្រឆាំង និងប្រយុទ្ធតបខ្មែរក្រហមវិញយ៉ាងហោចណាស់បីដងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដើម្បីឆ្លើយតបទៅនឹងការប្រឆាំងនេះ អង្គការបានចាប់ជនជាតិចាមទាំងអស់ទូទាំងប្រទេស យកទៅសម្លាប់ចោលយ៉ាងសាហាវឃោរឃៅ។

**សាន់ តីម៉ាណាស់** រស់នៅខេត្តកំពង់ចាម បានរំឭកពីការសម្លាប់រង្គាលរបស់ខ្មែរក្រហមទៅលើជនជាតិចាម ជាពិសេសការសម្លាប់ក្រុមគ្រួសាររបស់គាត់ក្នុងអំឡុងពេលនៃការបះបោរថា នៅសម័យសង្គមរាស្ត្រនិយម មានគ្រួសារជនជាតិចាមរាប់ពាន់គ្រួសាររស់នៅក្នុងភូមិរបស់ខ្ញុំ។ ពួកខ្មែរក្រហមបានសម្លាប់ពួកគេស្ទើរអស់។ ប្រជាជននៅក្នុងភូមិខ្ញុំ និងភូមិកោះផល ទទួលរងនូវអំពើព្រៃផ្សៃនេះច្រើនជាងគេ ពីព្រោះពួកយើងបានបះបោរប្រឆាំងនឹងពួកខ្មែរក្រហម។ ចំពោះគ្រួសារខ្ញុំវិញ ខ្មែរក្រហមសម្លាប់ឪពុកម្តាយរបស់ខ្ញុំ កូន ២នាក់ ចៅ ២នាក់ និងបងប្អូនបង្កើតរបស់ខ្ញុំទាំងអស់។ ខ្ញុំឮពាក្យចចាមអារ៉ាមថា សាច់ញាតិរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់ក្នុងឆ្នាំ១៩៧៨ នៅពេល តាមរកខ្ញុំ។ កូនស្រីរបស់ខ្ញុំឈ្មោះ រ៉ហ្វីអះ ព្រមទាំងប្តី និងកូន២នាក់ទៀត ត្រូវបានសម្លាប់ដោយគ្មានមូលហេតុ។[46]

---

[45] ជី ស្រីពេជ្រ, ឪពុកស្លាប់ដោយសារអង្គការចោទថាក្បត់ (មណ្ឌលគិរី៖ ឌីញូស៍ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ២០២៤)។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់តំណភ្ជាប់៖ https://thekrsurvivors.news/srov-ploeung/

[46] ផេង ពង្សរ៉ាស៊ី et all, ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ ២០២០) ទំព័រទី ៤៩ និង៥០។

ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលខ្មែរក្រហមឡើងកាន់កាប់អំណាច ចំនួនជនជាតិចិនបាន ថយចុះពី៤០០ ០០០នាក់ ទៅ ២០០ ០០០នាក់។ លោក បៃន ឃៀនិន បានអះអាងថា មានជនជាតិចិន ចំនួន ២២៥ ០០០នាក់ បានស្លាប់ក្នុងរបប ប៉ុល ពត។ បើតាមការស្រាវជ្រាវមួយចំនួនបានសន្និដ្ឋានថា ជនជាតិចិន មិនត្រូវបានគេសម្លាប់ដោយហេតុផលជាតិសាសន៍នោះទេ ប៉ុន្តែដោយសារឋានៈសង្គម ព្រោះ ថាពួកជនជាតិចិន គឺជាអ្នកទីក្រុង និងពួកមូលធន។ ការសន្និដ្ឋានខាងលើនេះ គឺបានមកពីលោក វៀលមត់ ត៍ នៅឆ្នាំ១៩៨២, ជនជាតិអូស្ត្រាលី ឈ្មោះ បៃន ឃៀនិន នៅឆ្នាំ១៩៩០ និងអ្នកទ្រឹស្តីផ្សេងទៀត ក៏បាន លើកឡើងប្រហាក់ប្រហែលនេះដែរ លើកលែងតែ លោកស្រី អេលីហ្សាបែត បេកខ័រ ដែលនិយាយថាជន ជាតិចិនត្រូវបានទទួលរងគ្រោះដោយសារការប្រកាន់ពូជសាសន៍។[47]

ក្រោយមកទៀត អង្គការបានស្រាវជ្រាវរកចាប់ខ្មាំងបន្ថែមទៀត ក្នុងនោះក៏មានកម្មាភិបាលរបស់ ខ្មែរក្រហមខ្លួនឯងដែរ។ អង្គការគិតថា នៅក្នុងជួរបដិវត្តន៍របស់ខ្លួន មានជនបង្កប់ដែលជាភ្នាក់ងារសម្ងាត់ ឱ្យទៅបរទេស ដូចជា សេ.អ៊ី.អា របស់សហរដ្ឋអាមេរិក និងកា.ហ្សេ.បេ របស់វៀតណាម។ មកដល់ឆ្នាំ ១៩៧៦ អង្គការបានធ្វើ**បន្សុទ្ធកម្ម**ទៅលើបញ្ញវន្ត និងអ្នកដែលមានជាប់ខ្សែពាក់ព័ន្ធនឹង កុយ ធួន ដែលជា លេខាភូមិភាគឧត្តរ។ កំឡុងពេលធ្វើបន្សុទ្ធកម្ម អង្គការបានចាប់ខ្លួនរដ្ឋមន្ត្រីក្រសួងព័ត៌មានឈ្មោះ ហ៊ូ នឹម, ទីវ អុល និងមិត្តភក្តិរបស់គាត់ជាច្រើននាក់ទៀត រួមមាន ភោគ ឆាយ និងឌឿន ជាដើម ដែលមានគម្រោង ធ្វើរដ្ឋប្រហារ និងការបះបោរ បី-បួនលើក(ជាពិសេសការបះបោររបស់ជនជាតិចាម) ក្នុងរបបកម្ពុជាប្រជា ធិតេយ្យ។ ប៉ុន្តែ ផែនការទាំងនេះសុទ្ធតែទទួលបរាជ័យ ហើយបានធ្វើឱ្យការស្រាវជ្រាវរកខ្មាំងបង្កប់ផ្ទៃក្នុង មានសភាពកាន់តែខ្លាំងក្លាឡើង ដែលនាំទៅដល់ការធ្វើបន្សុទ្ធកម្មនៅទូទាំងប្រទេស។[48]

បន្ទាប់ពីបានបោសសម្អាតអតីតលេខាងភូមិភាគឧត្តរមុនគេ មជ្ឈិម ចាប់ផ្តើមធ្វើការបោសសម្អាត ភូមិភាគមួយទៀតគឺភូមិភាគពាយ័ព្យ។ អង្គការបានបញ្ជូនកម្មាភិបាលភូមិភាគនិរតី ដែលដឹកនាំដោយ ឈិ ត ជឿន ហៅថាតាម៉ុក ចុះទៅទៅបង្ក្រាបកម្មាភិបាលនៅភូមិភាគពាយ័ព្យ។ ការបោសសំអាតនេះ គឺធ្វើ ឡើងចាប់ពីកម្មាភិបាលថ្នាក់លើនៃភូមិភាគរហូតដល់ប្រជាជននៅក្នុងសហករណ៍។

នៅឆ្នាំ១៩៧៧ បន្ទាប់ពីមានការប៉ះទង្គិចគ្នា និងចាញ់សង្គ្រាមជាមួយវៀតណាមនៅភូមិភាគបូព៌ា ប៉ុល ពត ចាប់ផ្តើមអស់ជំនឿចិត្តជាមួយ សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា។ អង្គការបានចោទប្រកាន់ សោ ភឹម និងកម្មាភិបាលក្រោមបង្គាប់ថាក្បត់ជាមួយអង្គការ ចូលរួមជាមួយចលនាវៀតណាម ដើម្បីផ្តួលរំលំ បដិវត្តន៍។ នៅក្នុងរយៈពេលមួយខែ កម្មាភិបាលភូមិភាគបូព៌ា ប្រមាណរាប់រយនាក់ ត្រូវបានគេចាប់ដាក់គុក នៅទួលស្លែង ហើយមេបញ្ជាការនៃកងពលធំចំនួន ២របស់មជ្ឈឹម ដែលប្រចាំការនៅក្នុងភូមិភាគនេះត្រូវ បានចាប់ខ្លួន និងបានដាក់បញ្ចូលមនុស្សដែលគ្មានសេចក្តីស្មោះត្រង់ជាមួយ សោ ភឹម។ មជ្ឈឹមបានបោស

---

[47] ហ៊ាន សុខុម, ក្រុមជនជាតិភាគតិចនៅកម្ពុជា(ភ្នំពេញ៖សាស្ត្រា, ២០០៩) ទំព័រ២១៨។

[48] ផេង ពង្សរ៉ាស៊ី and et, ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(ភ្នំពេញ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០២០) ទំព័រទី៤៩។

សម្ភាតរចនាសម្ព័ន្ធបក្សប្រចាំតំបន់នានា ហើយយកទ័ពនៅក្នុងភូមិភាគបូព៌ាទាំងអស់មកគ្រប់គ្រងខ្លួនឯង។ បើទោះបីជាយ៉ាងណា សោ ភឹម និងកងទ័ពរបស់គាត់នៅតែគិតថាវាជាការភាន់ច្រឡំមួយ ហើយគាត់នៅតែចង់ធ្វើការបកស្រាយមួយ ដើម្បីឱ្យមជ្ឈឹមកែប្រែ។

ចន្លោះពីខែមិថុនា ដល់ខែកញ្ញា ឆ្នាំ១៩៧៨ ស្របពេលដែលការប៉ះទង្គិចជាមួយវៀតណាម តំបន់ភាគច្រើននៅក្នុងភូមិភាគបូព៌ាបានក្លាយទៅជាសមរភូមិរវាងកងទ័ពរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពបះបោរ។ មនុស្សប្រហែល ១សែននាក់នៅក្នុងភូមិភាគបូព៌ាត្រូវបានសម្លាប់ និងស្លាប់ក្នុងសមរភូមិ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានបញ្ជូនយោធាខ្មែរក្រហមពីភូមិភាគនិរតី ឱ្យទៅបង្ក្រាបជនក្បត់នៅភូមិភាគបូព៌ា។ ប្រជាជនរាប់ពាន់នាក់បានរត់ទៅកាន់ព្រំដែនវៀតណាម ដើម្បីគេចខ្លួនពីការសម្លាប់រង្គាលដែលផ្ទុះឡើងបន្ទាប់ពីការមកដល់នៃកងទ័ពទាំងនោះ។[49]

អង្គការ បានចោទប្រកាន់ប្រជាជននៅក្នុងភូមិភាគបូព៌ាថា «*ក្បាលយួនខ្លួនខ្មែរ*» និងបានជម្លៀសចេញពីស្រុកកំណើតរបស់ខ្លួន ដើម្បីទៅរស់នៅខេត្តបាត់ដំបង និងពោធិ៍សាត់។ ការជម្លៀសប្រជាជននេះដោយសារមិនចង់ឱ្យប្រជាជនរត់ភៀសខ្លួនចូលទៅទឹកដីវៀតណាមបន្តទៀត។ ប្រជាជនដែលបានជម្លៀសទាំងអស់មានមួយចំនួនបាត់បង់ជីវិតនៅពាក់កណ្ដាលផ្លូវ ដោយសារតែការពន្លិចកប៉ាល់របស់ខ្មែរក្រហម និងមួយចំនួនទៀតស្លាប់ដោយសារការសម្លាប់នៅតំបន់ខ្លួនទៅដល់ ហើយខ្លះទៀតស្លាប់ដោយសារការធ្វើការងារធ្ងន់ធ្ងរ គ្មានអាហារហូបគ្រប់គ្រាន់ រួមជាមួយការឈឺគ្មានថ្នាំព្យាបាល។

### *ខ្មាំងខាងក្រៅ*

*ខ្មាំងខាងក្រៅ* សំដៅទៅលើ ប្រទេសវៀតណាម, ប្រទេសថៃ, សហភាពសូវៀត, សហរដ្ឋអាមេរិក និងប្រទេសសង្គមនិយមមួយចំនួនទៀត។ ខ្មែរក្រហមគិតថា ប្រទេសវៀតណាម និងប្រទេសថៃ មានបំណងចង់យកទឹកដីរបស់ប្រទេសកម្ពុជា។ ជម្លោះព្រំដែនរវាងប្រទេសថៃ, វៀតណាម និងកម្ពុជា បានកើតមានជាបន្តបន្ទាប់ ក្រោយពីខ្មែរក្រហមឡើងកាន់អំណាច។ ប៉ុន្តែប្រសិនបើប្រៀបធៀបសង្គ្រាមរវាងប្រទេសកម្ពុជាជាមួយប្រទេសថៃ និងកម្ពុជាជាមួយប្រទេសវៀតណាមវិញ គឺមានលក្ខណៈផ្សេងគ្នា។ ការប្រយុទ្ធគ្នារបស់ប្រទេសកម្ពុជា ជាមួយប្រទេសថៃ កើតមាននៅតាមព្រំដែនបន្តិចបន្តួច ហើយមិនសូវបើកចំហាប៉ុន្មានទេ ហើយប្រទេសកម្ពុជានៅតែមានទំនាក់ទំនងការទូត និងទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសថៃដដែល។

អំពីសភាពការណ៍នៅតាមព្រំដែនថៃ៖ នៅថ្ងៃទី២៨ ខែសីហា ខ្មាំងថៃវាយចូលដីយើង ១កងអនុសេនាធំ ចម្ងាយពីព្រំដែន ១គីឡូម៉ែត្រកន្លះ នៅមុខផ្កាមរមាស យើងបានប្រយុទ្ធជាមួយវារយៈពេល ១

---

[49] ផេង ពង្សរ៉ាស៊ី et al, ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩), (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០២០) ទំព័រទី៤៩។

ម៉ោង វាបាក់ទ័ពរត់ទៅវិញអស់ ខ្មាំងមានងាប់ និងរបួសមួយចំនួន។ បន្ទាប់មក វាដឹកទ័ពមកបន្ថែមមួយចំនួនច្រើនទៀត យើងវាយវាម្តងទៀត វាថយទៅវិញអស់។ យើងយកបានសម្ភារវាមួយចំនួន មានគ្រាប់អែកែង អឹម ៧៩មួយចំនួន និងមួកពីដុងទឹក កាំបិតខ្លះ។ ខាងយើងបានបន្ថែមកងទ័ព ៥០នាក់ ទៅត្រៀមកន្លែងប្រយុទ្ធខាងមុខ។ នៅថ្ងៃបន្ទាប់ ខាងកើតត្រពាំងតៅជាប់នឹងផ្លាមរមាស មានយន្តហោះធុនមិចហោះលើភូមិចំនួនពីរដង ហើយនៅថ្ងៃទី៣០ ខែសីហា យន្តហោះខ្មាំងធុនមិចដដែលហោះលើព្រំដែនយើងខាងក្បាលស។[50]

នៅខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមមានទំនាស់ជាមួយវៀតណាម ក្នុងការដណ្តើមកោះរបស់ខ្មែរមួយចំនួនដែលបារាំងកាត់ទៅឱ្យវៀតណាមកាលពីពេលមុន។ បើតាមសៀវភៅ «សត្រូវបងប្អូនឯង» បាននិយាយថា នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានឡើងទៅត្រួតត្រាលើកោះភូកុក ឬក៏ខ្មែរហៅថា កោះត្រល់ បានមកពីការវាយលុកតាមផ្លូវសមុទ្រចូលត្រួតត្រាលើកោះនេះ។ ប្រាំថ្ងៃក្រោយមកខ្មែរក្រហម បានវាយយកកោះ ពូឡូប៉ង់ហ្សង់ វៀតណាមហៅ ថូជូ ហើយខ្មែរហៅ កោះក្រចកសេះ ថែមទៀត។ ក្រោមការគំរាមកំហែងដោយអាវុធ ប្រជាជនវៀតណាម ៥០០នាក់ត្រូវបានបណ្តេញចេញពីទីនោះ។ ពីរសប្តាហ៍ក្រោយនៃការកាន់កាប់របស់ខ្មែរក្រហម វៀតណាមបានបើកការវាយបកមកវិញ និងបានសម្លាប់ខ្មែរក្រហមអស់ជាច្រើននាក់ និងចាប់បានឈ្លើយសឹកចំនួន ៣០០នាក់។

សូមបញ្ជាក់ថា ការដណ្តើមកាន់កាប់កោះខ្មែរមួយចំនួនដែលបានកាត់នៅក្នុងសម័យអាណានិគមបារាំង នៅតំបន់ឈូងសមុទ្រថៃ គឺជាជំហានដំបូងនៃជម្លោះរវាងប្រទេសទាំងពីរ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច។ ជាការពិតណាស់ ភាពល្អក់កករជាមួយវៀតណាមមិនមែនបញ្ចប់តែត្រឹមនេះទេចំពោះបញ្ហាព្រំដែនសមុទ្រ និងព្រំដែនដីគោក គឺនៅតែធ្វើឱ្យមានការប្រយុទ្ធគ្នា និងត្រូវបន្តការចរចាជាលក្ខណៈការទូតជាបន្តបន្ទាប់។ នៅឆ្នាំ១៩៧៦ បន្ទាប់ពីទទួលបានជំនួយយោធាយ៉ាងច្រើនពីចិន រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានបង្កើនការប្រយុទ្ធជាមួយ វៀតណាមកាន់តែខ្លាំងឡើងៗ។ នៅខែធ្នូ ឆ្នាំ១៩៧៧ រដ្ឋាភិបាលរបស់ខ្មែរក្រហម បានកាត់ផ្តាច់ទំនាក់ទំនងការទូតទាំងស្រុងជាមួយវៀតណាម និងបើកការប្រយុទ្ធគ្នានៅតាមព្រំដែនកាន់តែខ្លាំងក្លា។

*ការកម្ទេច និងបោសសម្អាតភូមិភាគបូព៌ា*

ភូមិភាគបូព៌ាដែលមាន ៥តំបន់ដឹកនាំដោយ សោ ភឹម ក្រោយមកបានសម្លាប់ខ្លួនដើម្បីគេចចេញពីការសម្លាប់ «កម្ទេច» ដោយមេដឹកនាំខ្មែរក្រហមចោទប្រកាន់ថា សោ ភឹម ក្បត់នឹងអង្គការបម្រើផលប្រយោជន៍វៀតណាម។ សោ ភឹម គឺជាសមាជិកម្នាក់ក្នុងចំណោម ៥ របស់គណៈអចិន្ត្រៃយ៍ ប.ក.ក។ សោ ភឹម ក៏ជាសមាជិកម្នាក់ក្នុងរង្វង់មេដឹកនាំបដិវត្តន៍មួយចំនួនដែលស្រប និងទទួលរាល់សកម្មភាព

[50] ឯកសារលេខ D01789 តេឡេក្រាម គោរពជូន គណៈ៨៧០ ជាទីស្នេហា និងរឭក (សូមរាយការណ៍ពីសភាពការណ៍ខ្មាំងខាងក្រៅ នៅតាមព្រំដែនប្រទេសថៃ) (ទូរលេខ ៦០, ខ្ទង់ ១៤៧៣) ដោយបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ទាំងឡាយដែលប្រើកម្លាំងបាយ និងឧបាយកលរបស់បដិវត្តន៍ ហើយគាត់បានគោរពរាល់បទបញ្ជាទាំងអស់ដែលដាក់ចេញដោយមជ្ឈិម ប.ក.ក។ ឆ្នាំ១៩៧៨ សោ ភឹម គិតថា អង្គការបានទុកចិត្តទាំងស្រុងលើរាល់សកម្មភាពបដិវត្តន៍របស់គាត់ដូច្នោះហើយទើបគាត់បានធ្វើដំណើរមកជួប ប៉ុល ពត ដោយផ្ទាល់ដើម្បីបញ្ជាក់ពីភាពស្មោះត្រង់របស់គាត់ចំពោះអង្គការ ប៉ុន្តែគាត់បានធ្វើអត្តឃាតក្រោយពីគណៈមជ្ឈិម ប.ក.ក បានឡោមព័ន្ធ។[51]

ភូមិភាគបូព៌ាត្រូវបានបោសសម្អាតយ៉ាងគំហុកក្រោយពីការធ្វើអត្តឃាតរបស់លេខាភូមិភាគបូព៌ា សោ ភឹម ។ ការបោសសម្អាតកម្មាភិបាលក្នុងភូមិភាគបូព៌ា ជាមូលហេតុធ្វើឱ្យមានការជម្លៀសប្រជាជននៅភូមិភាគនេះនៅក្នុងដំណាក់កាលទី៣ ទៅភូមិភាគពាយ័ព្យ និងការលត់ដំនៅការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ព្រមទាំងសកម្មភាពសួរសម្លើយ និងការសម្លាប់កម្មាភិបាលភូមិភាគនេះនៅគុកទួលស្លែង។

*សារតារដំបូងនៃការបោសសម្អាតភូមិភាគបូព៌ា៖* នៅពាក់កណ្តាលឆ្នាំ១៩៧៦ កម្មាភិបាលចំនួន ២ រូបនៅភូមិភាគបូព៌ា គឺ សួស នៅ ហៅ ឈូក អតីតលេខាតំបន់២៤, និង ចាន់ ចក្រី ហៅ នៅ អតីតកម្មាភិបាលកងពល១៧០, ត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ថាជាភ្នាក់ងារ សេ.អ៊ី.អា, កា.ហ្សេ.បេ, និងវៀតណាម, ហើយនាំឱ្យមានការចាប់ខ្លួនកម្មាភិបាលភូមិភាគបូព៌ាជាហូរហែដែលភាគច្រើនត្រូវបានគេបញ្ជូនទៅមន្ទីរស-២១។ តាមរយៈចម្លើយសារភាពរបស់អ្នកទាំងពីរនៅថ្ងៃទី៣០ ខែមេសា ខែឆ្នាំ១៩៧៧ ស៊ាត ឆែ ហៅ ទុំ អតីតលេខតំបន់២២ ត្រូវបានគេចាប់ខ្លួន។ ចម្លើយសារភាពដែលទាញចេញពី ទុំ នៅស-២១ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៧៧ បាននាំឱ្យមានការបោសសម្អាតធំមួយនៅតំបន់២២នៃភូមិភាគបូព៌ា។[52]

ចាប់ពីពាក់កណ្តាលខែសីហា ឆ្នាំ១៩៧៧ ការចាប់ខ្លួន និងការបញ្ជូនខ្លួននៅក្នុងភូមិភាគបូព៌ា បានរៀបចំឡើងយ៉ាងហ្មត់ចត់ដោយ សុន សេន និង កែ ពក តាមរយៈការប្រើប្រាស់កម្លាំងអចិន្ត្រៃយ៍របស់គណៈមជ្ឈិម អង្គភាពមកពីភូមិភាគកណ្តាល និងកងទ័ពរបស់អតីតភូមិភាគនិរតីដែលស្ថិតនៅក្រោមបញ្ជារបស់គណៈមជ្ឈិម។ នៅក្នុងខែមីនា ឆ្នាំ១៩៧៨ ការបោសសម្អាតដែលកើនឡើងយ៉ាងធំមួយលើកម្មាភិបាល និងយុទ្ធជននៅភូមិភាគបូព៌ាបានកើតឡើងនៅស្វាយរៀង (តំបន់២៣) ដោយក្រោយមកមានការចាប់ខ្លួន និងសម្លាប់ចោលកាន់តែច្រើនឡើងៗចាប់ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ១៩៧៨ នៅតាមបណ្តាទីកន្លែងដទៃទៀតនៅក្នុងភូមិភាគបូព៌ា ដែលក្នុងពេលនោះ សោ ភឹម លេខាភូមិភាគបូព៌ា បានធ្វើអត្តឃាតដោយមិនចង់ឱ្យគេចាប់ខ្លួន។ ក្នុងខែមិថុនា ឆ្នាំ១៩៧៨ នួន ជា បានក្លាយជាលេខាភូមិភាគនេះក្នុងរយៈពេលខ្លីក្រោយអត្តឃាតរបស់ សោ ភឹម។ កម្មាភិបាលរាប់រយនាក់ត្រូវបានបញ្ជូនពីភូមិភាគបូព៌ាទៅមន្ទីរស-

---

[៥១]ចំណងជើងសៀវភៅ នៅពេលដែលសង្គ្រាមរត់ទៅ, និពន្ធដោយអេលីហ្សាបែត បេកខ័រ, បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០០៥, ទំព័រទី៤១៤។

[52]ឯកសារលេខD427 (១៥ ខែកញ្ញា ឆ្នាំ២០១០) ដីកាដំណោះស្រាយសំណុំរឿង ០០២ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ទំព័រទី៦៤។

២១ ខណៈពេលដែលអ្នកផ្សេងទៀតត្រូវបានសម្លាប់នៅនឹងកន្លែង ឬត្រូវផ្លាស់កន្លែងទៅកាន់តំបន់ផ្សេងទៀត។[53] ភូមិភាគបូព៌ាមានការចាប់ខ្លួនមនុស្សបានកើនឡើងរហូតដល់ ១,១៦៥នាក់ ដោយមានការចាប់ខ្លួនមនុស្សប្រហែល ៥០០នាក់ តែក្នុងខែមិថុនា ឆ្នាំ១៩៧៨ ក្រោយការធ្វើអត្តឃាតរបស់ សោ ភឹម។ ក្នុងបទសម្ភាសន៍មួយកាលពីឆ្នាំ២០០៦ ខៀវ សំផន បានលើកឡើងថា វន វ៉េត និង សោ ភឹម ត្រូវបានចាប់ខ្លួនដោយសារតែអ្នកទាំងពីរជាភ្នាក់ងាររបស់យួន។[54]

## *ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី៣*

ការផ្លាស់ទីលំនៅប្រជាជន[55]ដំណាក់កាលទី៣ នៅចុងឆ្នាំ១៩៧៧ ដល់ចុងឆ្នាំ១៩៧៨ ប្រជាជនជាច្រើនដែលរស់នៅភូមិភាគបូព៌ាដែលជាភូមិភាគកំណត់ដោយប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាល ប.ក.ក ត្រូវបានផ្លាស់ទីលំនៅពីភូមិភាគនេះ។ តាមការបំភ្លឺរបស់សាក្សីជាច្រើនបង្ហាញថា ដំណើរការផ្លាស់ទីលំនៅបានចាប់ផ្តើមនៅក្នុងបរិបទនៃការបោសសម្អាតដែលកើតឡើងនៅក្នុងភូមិភាគបូព៌ា។ ចំនួនដ៏ច្រើននៃប្រជាជនទាំងនោះដែលត្រូវបានផ្លាស់ទីលំនៅមកពីខេត្តព្រៃវែង និងស្វាយរៀង ត្រូវបានបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់ ឬខេត្តបាត់ដំបង ដែលខេត្តទាំងពីរនេះស្ថិតនៅភូមិភាគពាយ័ព្យ។[56]

ការជម្លៀសប្រជាជនដោយបង្ខំបែបនេះ ធ្វើឡើងលើប្រជាជនរស់នៅក្នុងភូមិភាគបូព៌ាដែលនៅពេលនោះមាន សង្គ្រាមកាន់តែខ្លាំងឡើងរវាងរបបខ្មែរក្រហម និងប្រទេសវៀតណាម និងចំពេលដែលរបបនេះកំពុងតែបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា។ អ្នកជម្លៀសទាំងនោះ គឺជាកម្មាភិបាល និងកងទ័ពខ្មែរក្រហម ឬប្រជាជនដែលគេចោទថាជាជនក្បត់ និងមានទំនាក់ទំនងជាមួយវៀតណាម ឬ សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា និងប្រជាជនថ្មីដែលជម្លៀសចេញពីភ្នំពេញ និងទីប្រជុំជននានា។ ប្រជាជនជម្លៀសដំណាក់កាលទីបីភាគច្រើនរស់នៅខេត្តស្វាយរៀង និងព្រៃវែង ត្រូវទៅកាន់ខេត្តពោធិ៍សាត់ និងបាត់ដំបង។ ការផ្លាស់ទីលំនៅប្រជាជន ក្នុងដំណាក់កាលនេះមានការសម្រេចរបស់មជ្ឈិមរបស់ ប.ក.ក និងជាប់ពាក់ព័ន្ធនឹងការបោសសម្អាតភូមិភាគបូព៌ាដែលបានកើតឡើងដោយសារការភ័យខ្លាចការបង្កប់ខ្លួនរបស់វៀតណាមនៅក្នុងជួរ ប.ក.ក ក្នុងភូមិភាគបូព៌ាដើម្បីរៀបចំរដ្ឋប្រហារ។ ការសម្រេចផ្លាស់ប្តូរទីលំនៅនេះ គឺនៅក្នុងកិច្ចប្រជុំនៅភូមិភាគពាយ័ព្យ តា ម៉ុក បានហៅ សោ ភឹម ថាជាជនក្បត់ ហើយបាននិយាយថា «អង្គការ» នឹងធ្វើការផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគបូព៌ាទៅកាន់ភូមិភាគពាយ័ព្យដើម្បីតាមដានថា

---

[53]ស្ងួន, ទំព័រទី៦៥។

[54]ស្ងួន, ទំព័រទី៣៩៨។

[55]សៀវភៅការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម, បោះពុម្ពដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ, ឆ្នាំ២០១៤, ទំព័រទី១០ សរសេរថា «នៅក្នុងរបបខ្មែងក្រហមប្រជាជនត្រូវបានជម្លៀសពីមួយកន្លែងទៅមួយកន្លែងតាមមធ្យោបាយផ្សេងៗដូចជារថភ្លើង រថយន្តឯកជន រថយន្តទាហាន ទូក កាណូត រទេះគោ ត្រាក់ទ័រ និងថ្មើរជើង» ។

[៥៦]ស្ងួន, ទំព័រទី៩៣។

តើប្រជាជនភូមិភាគបូព៌ាប្រឆាំងមាគ៌ារបស់បក្ស និង/ឬ ថាតើអ្នកទាំងនោះមានពាក់ព័ន្ធជាប់ខ្សែរយៈជាមួយវៀតណាមឬយ៉ាងណា។[57]

## *ការលត់ដំនៅការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង*

កម្មាភិបាលមួយចំនួនដែលរួមមាន អតីតកម្មាភិបាល និងយុទ្ធជនរបស់ភូមិភាគបូព៌ា ត្រូវបានដកឱ្យធ្វើការនៅតាមការដ្ឋានដើម្បី «លត់ដំ» ដូចជានៅទីកន្លែងសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។[58] ជាញឹកញាប់ កងទ័ពត្រូវបានដកហូតអាវុធមុននឹងត្រូវបានចាត់តាំងឱ្យទៅបំពេញសកម្មភាពមិនមែនយោធា ជាពិសេសនៅពេលបោសសម្អាត «សមាសភាពមិនល្អ» (ឧទាហរណ៍ៈ នៅពេលបញ្ជូនកងទ័ពពីភូមិភាគបូព៌ាទៅកាន់ការដ្ឋានប្រលានយន្តហោះកំពង់ឆ្នាំង)។ «កងទ័ពគ្មានអាវុធចំនួន ៥០០០នាក់ត្រូវបានដឹកមកពីខេត្តស្វាយរៀងតាមឡានកងទ័ពឆ្ពោះទៅកាន់ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងដោយឆ្លងកាត់តាមភ្នំពេញ»។[59] រីឯកម្មាភិបាលខ្មែរក្រហមភូមិភាគបូព៌ាប្រមាណ ៣០០នាក់ ត្រូវបានចាត់ទុកថាជាអ្នកទោសត្រូវបានសម្លាប់នៅគុកទួលស្លែងក្រោមបញ្ជារបស់ ឌុច អតីតប្រធានគុកទួលស្លែង និងនួន ជា ប្រធានរដ្ឋសភាសម័យខ្មែរក្រហម៕[60]



*(មន្ទីរនីរសោភូមិភាគ ស្ថិតនៅក្នុងខេត្តស្វាយរៀង នៃភូមិភាគបូព៌ា។ ប្រភពរូបថតៈ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)។*

---

[57]ស្នួន, ទំព័រទី292 និងទំព័រទី៤១៣។

[58]ឯកសារលេខD427 (១៥ ខែកញ្ញា ឆ្នាំ២០១០) ដីកាដំណោះស្រាយសំណុំរឿង ០០២ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ទំព័រទី៦៣-៦៤។

[59]ស្នួន, ទំព័រទី95។

[60]ស្នួន, ទំព័រទី៣២២។